# មាតិកា

## I_ខុទ្ទកាល័យព្រះមហាក្សត្រ

### ព្រះរាជក្រឹត្យ


០៨-៥-២០០៦ -ព្រះរាជក្រឹត្យ នស/រកត/០៥០៦/២២០ ស្តីពីការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **វ៉ាយ ធូម៉ាសហ្វ្រេន** (WHITE THOMAS FRANK) ជនជាតិអាមេរិក សញ្ជាតិអាមេរិក កើតនៅឈីកាហ្គូ អ៊ីលលីណយ សហរដ្ឋអាមេរិក ៣៨៨៤

០១-៦-២០០៦ -ព្រះរាជក្រឹត្យ នស/រកត/០៦០៦/២៤៩ ស្តីពីការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **ស៊ុម ប៉ូឈីផល** (SHUM PO CHI PAUL) ជនជាតិចិនសញ្ជាតិចិន កើតនៅក្រុងហុងកុង សាធារណរដ្ឋប្រជាមានិតចិន ៣៨៨៥

១០-៦-២០០៦ -ព្រះរាជក្រឹត្យ នស/រកត/០៦០៦/២៦១ ស្តីពីការតែងតាំងមន្ត្រីរាជការ ៣៨៨៦


## II_រាជរដ្ឋាភិបាល

### ១_អនុក្រឹត្យ


១៥-៦-២០០៦ -អនុក្រឹត្យលេខ ៤២៧ អនក្រ.តត ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ ៣៨៨៨

១៥-៦-២០០៦ -អនុក្រឹត្យលេខ ៤២៨ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៣៨៨៩

១៥-៦-២០០៦ -អនុក្រឹត្យលេខ ៤២៩ អនក្រ.តត ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ ៣៨៩០

១៥-៦-២០០៦ -អនុក្រឹត្យលេខ ៤៣០ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៣៨៩១

១៦-៦-២០០៦ -អនុក្រឹត្យលេខ ៤៣១ អនក្រ.តត ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ ៣៨៩២

១៦-៦-២០០៦ -អនុក្រឹត្យលេខ ៤៣២ អនក្រ.តត ស្តីពីការជូនមេដាយការងារ ៣៨៩៣


### ២_សេចក្តីសម្រេច


១៦-៦-២០០៦ -សេចក្តីសំរេចលេខ ២៤ សសរ ស្តីពីការតែងតាំងសមាសភាពគណៈកម្មាធិការជាតិដោះស្រាយបញ្ហាជនអនាថា ៣៨៩៤

១៦-៦-២០០៦ -សេចក្តីសំរេចលេខ ២៥ សសរ ស្តីពីការបង្កើតក្រុមការងារអន្តរក្រសួងដើម្បីអនុវត្តកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាល នៃសាធារណរដ្ឋសង្គមនិយមវៀតណាម ស្តីពីកិច្ចសហប្រតិបត្តិការទ្វេភាគីដើម្បីលុបបំបាត់ការជួញដូរស្ត្រី និងកុមារ និងជួយដល់ជនរងគ្រោះដោយសារការជួញដូរ ៣៨៩៧

## III-ការងារបណ្ដាក្រសួង

### ១-ទីស្ដីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ


១២-៦-២០០៦ -ប្រកាសលេខ ៤២៥ សហវ.ប្រក ស្ដីពីការបង្កើតគណៈកម្មការឧទ្ធរណ៍សំរាប់យន្តការអធិការកិច្ចទំនិញមុនពេលផ្ទុក ៣៩០១

១៦-៦-២០០៦ -ប្រកាសលេខ ៤៣១ សហវ ស្ដីពីការដាក់ឱ្យប្រើប្រាស់គំរូរបាយការណ៍ហិរញ្ញវត្ថុ សំរាប់សហគ្រាសធុនតូច និងមធ្យម ៣៩០៣

១៤-៦-២០០៦ -សេចក្ដីសំរេចលេខ ០០៥ សសរ.សហវ.ពជ ស្ដីពីការកែប្រែសមាសភាពអនុគណៈកម្មការវាយតំលៃដីមិនទាន់ប្រើប្រាស់ ខេត្តកំពង់ធំ ៣៩៦៦

១៤-៦-២០០៦ -សេចក្ដីសំរេចលេខ ០០៦ សសរ.សហវ.ពជ ស្ដីពីការកែប្រែសមាសភាពអនុគណៈកម្មការវាយតំលៃដីមិនទាន់ប្រើប្រាស់ ខេត្តសៀមរាប ៣៩៦៩


### ២-ទីស្ដីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម


០៤-៥-២០០៦ -លិខិតលេខ ១១៩៩ ពណ.នតក ស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ស៊ូ ជីង ផៅវ័រ ខមភេនី** ៣៩៧២

០៥-៥-២០០៦ -លិខិតលេខ ១២០១ ពណ.នតក ស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ញូវគ្រេន(ខេមបូឌា)ភីធីអ៊ី អិលធីឌី** ៣៩៧៤

០៥-៥-២០០៦ -លិខិតលេខ ១២០៦ ពណ.នតក ស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ដ្រេហ្គន វ៉ាយស៍ ហ្គ្រោវីង អ៊ិនវេសមេន (ឌី.អេ.ជី)** ៣៩៧៦

០៥-៥-២០០៦ -លិខិតលេខ ១២០៧ ពណ.នតក ស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ហ្គោដាយ គ្រុប (ខេមបូឌា)** ៣៩៧៨

០៥-៥-២០០៦ -លិខិតលេខ ១២០៨ ពណ.នតក ស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ឆេដ អ៊ិនធើណេសិនណល ខូអប ភើរេសិន** ៣៩៨០

០៥-៥-២០០៦ -លិខិតលេខ ១២០៩ ពណ.នតក ស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ជីអូលីង ឌីស្ទ្រីប៊្យូសិន** ៣៩៨២

០៥-៥-២០០៦ -លិខិតលេខ ១២១៣ ពណ.នតក ស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ខាណា (ខេមបូឌា)** ៣៩៨៤

០៥-៥-២០០៦ -លិខិតលេខ ១២២១ ពណ.នតក ស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ជុង គីយុង** ៣៩៨៦

| | | |
|---|---|---|
| ០៨-៥-២០០៦ | -លិខិតលេខ ១២២៣ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ឡាយអិន វិចតូរីយ៉ា ខមភេនី អិលធីឌី** | ៣៩៨៨ |
| ០៨-៥-២០០៦ | -លិខិតលេខ ១២២៤ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ជេ អេស អិម ខន្សូនៀល មេនសិន I** | ៣៩៩០ |
| ០៨-៥-២០០៦ | -លិខិតលេខ ១២២៦ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ថាណាហ្គាធី ខូ អិលធីឌី** | ៣៩៩២ |
| ០៨-៥-២០០៦ | -លិខិតលេខ ១២២៩ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ប៉េង ហុង ហួត** | ៣៩៩៣ |
| ០៨-៥-២០០៦ | -លិខិតលេខ ១២៣០ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ហាយហ្វារ គ្លូបិល** | ៣៩៩៥ |
| ០៨-៥-២០០៦ | -លិខិតលេខ ១២៣១ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ប្លូ វែល ខេមីខល (ខេមបូឌា)** | ៣៩៩៧ |
| ០៨-៥-២០០៦ | -លិខិតលេខ ១២៣២ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ប៊ី ធី & ឌី** | ៣៩៩៩ |
| ០៨-៥-២០០៦ | -លិខិតលេខ ១២៣៦ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អិល.ធី.អិល** | ៤០០១ |
| ០៩-៥-២០០៦ | -លិខិតលេខ ១២៣៧ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ខូវៀន អេនធើធេនមេន លីមីធីត** | ៤០០៣ |
| ០៩-៥-២០០៦ | -លិខិតលេខ ១២៣៨ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ញូ ខេម** | ៤០០៥ |
| ០៩-៥-២០០៦ | -លិខិតលេខ ១២៤០ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ស៊ី អិន អិល ភីធីអ៊ី អិលធីឌី** | ៤០០៧ |
| ០៩-៥-២០០៦ | -លិខិតលេខ ១២៤១ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ភី ស៊ី អ (ខេមបូឌា) ខូ អិលធីឌី** | ៤០០៩ |
| ០៩-៥-២០០៦ | -លិខិតលេខ ១២៤២ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ជេ អេស អិម ខន្សូនៀល មេនសិន II** | ៤០១១ |
| ០៩-៥-២០០៦ | -លិខិតលេខ ១២៤៤ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **សិនដា (ខេមបូឌា) ត្រេឌីង** | ៤០១៣ |
| ០៩-៥-២០០៦ | -លិខិតលេខ ១២៤៥ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អ.អេស.អិន គ្រុប** | ៤០១៥ |

នស/រកត/០៥០៦/២២០

# ព្រះរាជក្រឹត្យ

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានត្ថមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋារាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

**ត្រាស់បង្គាប់**

**មាត្រា ១ៈ** ផ្តល់សញ្ជាតិខ្មែរ តាមសញ្ញាតូបនីយកម្មដល់លោក **វ៉ាយ ធូម៉ាសហ្វ្រេង** (WHITE THOMAS FRANK) ជនជាតិអាមេរិក សញ្ជាតិអាមេរិក កើតថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ១៩៣៦ នៅឈីកាហ្គូ អ៊ីលលីណយ (Chicago Illinois) សហរដ្ឋអាមេរិក។

**មាត្រា ២ៈ** សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ៈ** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះ តទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

លេខៈ៧១១ ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ ថ្ងៃទី១០ ខែ[illegible] ឆ្នាំ២០០៦
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ឈាឌី តាន់**

ពរល.០៦០៥.២៣០

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ៨ ខែឧសភា ឆ្នាំ ២០០៦*

# ព្រះរាជក្រឹត្យ

នស/រកត/០៦០៦/២៤៩

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស / រកត / ០៧០៤ / ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្ម ដល់លោក **ស៊ុម ប៉ូជីភល (SHUM PO CHI PAUL)** ជនជាតិចិន សញ្ជាតិចិន កើតថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ ១៩៦៧ នៅក្រុងហុងកុង សាធារណរដ្ឋប្រជាមានិតចិន ។

**មាត្រា ២ :** សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយមានសំរេច នូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះ តទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

លេខ : ២៤១ ច.ល
**ជើងម្ចាស់ចម្លងចែក**
រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ២០០៦
**អគ្គលេខាធិការរងរាជរដ្ឋាភិបាល**

**ប៊ុន ឈិនកេន**

ចរល.០៦០៦.២៦០

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ១ ខែ មិថុនា ឆ្នាំ ២០០៦

# ព្រះរាជក្រឹត្យ

នស/រកត/០៦០៦/២៦១

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជ្យរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងរបស់រដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់លទ្ធផលនៃសម័យប្រជុំលើកទី ៤ នីតិកាលទី ៣ នៃរដ្ឋសភា នាថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០០៦ ស្តីពីការជ្រើសតាំងរចនាសម្ព័ន្ធ និងថ្នាក់ដឹកនាំរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់សេចក្តីសម្រេចលេខ ៤៧៦ រស. ចុះថ្ងៃទី ០៣ ខែ ឧសភា ឆ្នាំ ២០០៦ ស្តីពីរបបប្រាក់បំណាច់ របបធានារ៉ាប់រងសង្គម និងរបបបេសកកម្មរបស់តំណាងរាស្ត្រ
- បានទ្រង់យល់សេចក្តីសម្រេចរួមលេខ ០១ ពរក. ចុះថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ២០០៤ របស់ស្ថាប័ននីតិប្បញ្ញត្តិស្តីពី បៀវត្សមូលដ្ឋាន និងប្រាក់បំណាច់ផ្សេងៗរបស់មន្ត្រីរាជការនៃក្រុមនីតិប្បញ្ញត្តិ
- បានទ្រង់យល់សេចក្តីស្នើរបស់ សម្តេច ហេង សំរិន ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១.-** ត្រូវបានតែងតាំង :

១- លោកជំទាវ **ម៉ែន សុមនា** ជាជំនួយការ ឯកឧត្តម **ម៉ែន បញ្ញា** ប្រធានគណៈកម្មការ សិទ្ធិមនុស្ស ទទួលពាក្យបណ្តឹង អង្កេត និង ទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា មានឋានៈស្មើ អគ្គនាយក

២- ឯកឧត្តម **អ៊ុក ផល្លា** ជាជំនួយការ ឯកឧត្តម **ចាម យៀប** ប្រធានគណៈកម្មការ សេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារ និង សវនកម្ម មានឋានៈស្មើ អគ្គនាយក

៣- ឯកឧត្តម **គីម ចន្ទនា** ជាជំនួយការ ឯកឧត្តម **ឈី ឆុង** ប្រធានគណៈកម្មការ ផែនការ វិនិយោគ កសិកម្ម អភិវឌ្ឍន៍ជនបទ បរិស្ថាន និងធនធានទឹក មានឋានៈស្មើ អគ្គនាយក

៤- ឯកឧត្តម **គី ចណ្ណជារ៉ា** ជាជំនួយការ ឯកឧត្តម **យឹម សុវណ្ណ** ប្រធានគណៈកម្មការ មហាផ្ទៃ ការពារជាតិ អង្កេត បោសសំអាត និងមុខងារសាធារណៈ មានឋានៈស្មើ អគ្គនាយក

៥- ឯកឧត្តម **ឡៅ ម៉ុងហៃ** ជាជំនួយការ ឯកឧត្តម **សុន ឆ័យ** ប្រធានគណៈកម្មការ កិច្ចការបរទេស សហប្រតិបត្តិការអន្តរជាតិ ឃោសនាការ និងព័ត៌មាន មានឋានៈស្មើ អគ្គនាយក

៦- ឯកឧត្តម **ចំន្ទ សុខវណ្ណារ៉េត** ជាជំនួយការ ឯកឧត្តម **ឯក សំអុល** ប្រធានគណៈកម្មការ នីតិកម្ម និងយុត្តិធម៌ មានឋានៈស្មើ អគ្គនាយក

៧- ឯកឧត្តម **សារិន ប្រសិទ្ធិ** ជាជំនួយការ ឯកឧត្តម **ម៉ុម ជីមហ៊ុយ** ប្រធានគណៈកម្មការ អប់រំ យុវជន កីឡា ធម្មការ កិច្ចការសាសនា វប្បធម៌ និងទេសចរណ៍ មានឋានៈស្មើ អគ្គនាយក

៨- ឯកឧត្តម **សុខ ម៉ិនថា** ជាជំនួយការ លោកជំទាវ **ចូ ឈួន** ប្រធានគណៈកម្មការ សុខាភិបាល សង្គមកិច្ច អតីតយុទ្ធជន យុវនីតិសម្បទា ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងកិច្ចការនារី មានឋានៈស្មើ អគ្គនាយក

៩- ឯកឧត្តម **ម៉ី សំណាង** ជាជំនួយការ លោកជំទាវ **គី លំអុង** ប្រធានគណៈកម្មការ សាធារណការ ដឹកជញ្ជូន ទូរគមនាគមន៍ ប្រៃសណីយ៍ ឧស្សាហកម្ម រ៉ែ ថាមពល ពាណិជ្ជកម្ម រៀបចំដែនដី នគរូបនីយកម្ម និងសំណង់ មានឋានៈស្មើ អគ្គនាយក

**មាត្រា ២.-** ប្រធានរដ្ឋសភា និង នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្ថលេខាតទៅ ។

**មាត្រា ៣.-** ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ថលេខានេះតទៅ ។

**ព្រះហស្ថលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

នស/រកត/០៦០៦/២៥២

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញ,ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ២០០៦

លេខ : ២៥៤ ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ,ថ្ងៃទី ១៦ ខែមិថុនា ឆ្នាំ២០០៦
**អគ្គលេខាធិការរងរាជរដ្ឋាភិបាល**

**ឃុន ជិនកេន**

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ:...៤២៧ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការផ្តល់មេដាយមុនីសារាភ័ណ្ឌ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ អភិបាលខេត្តឧត្តរមានជ័យ

### សម្រេច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយមុនីសារាភ័ណ្ឌ** តាមលំដាប់ថ្នាក់ ជូនសប្បុរសជន ចំនួន០៣រូប ដែលមានស្នាដៃល្អ និងគុណបំណាច់ ក្នុងការចូលរួមជួយកសាង អគារសិក្សា និងផ្លូវថ្នល់ នៅក្នុងខេត្តឧត្តរមានជ័យ ដូចមានរាយនាមខាងក្រោម :-

**ក-មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ សេនា :**

១-ឧកញ៉ា **លី យ៉ុងផាត់** ជួយកសាងសាលារៀន ០១ខ្នង មាន០៥បន្ទប់ នៅឃុំអូរស្មាច់ ស្រុកសំរោង ចំណាយអស់ថវិកា ចំនួន ២៥.០០០ ដុល្លារ

២-ឧកញ៉ា **លឹម ហេង** ជួយកសាងសាលារៀន ០១ខ្នង មាន០៥បន្ទប់ នៅឃុំសំរោង ស្រុកសំរោង ចំណាយអស់ថវិកា ចំនួន ២៥.០០០ ដុល្លារ

**ខ-មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ អស្សឫទ្ធិ :**

-លោក **អ៊ិន ស៊ីភាត់** ជួយទិញប្រេងឈូសឆាយផ្លូវ ពីអូរស្មាច់ មកសំរោង ចំណាយអស់ថវិកា ចំនួន ២០.០០០ ដុល្លារ

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលខេត្តឧត្តរមានជ័យ ត្រូវអនុវត្តអនុក្រឹត្យ នេះ អោយទទួលបានលទ្ធផលល្អ ។/.

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០០៦

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**
លេខ: ៤៣៨ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស ឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
-តាមសំណើរបស់ ប្រធានគណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជនដែលត្រូវជូនគ្រឿងឥស្សរិយយស

## សម្រេច

**មាត្រា១:** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនសប្បុរសជន ចំនួន០៣រូប ដែលមានស្នាដៃល្អក្នុងការចូលរួមជួយថែរក្សាសម្បត្តិធម្មជាតិ ព្រមទាំងជួយការងារគ្រោះមហន្តរាយ នៅខេត្តឧត្តរមានជ័យ ដូចមានរាយនាមខាងក្រោម :-

១-លោក **ឈឹម ស៊ីខុន** មន្ត្រីសំរបសំរួលអចិន្ត្រៃយ៍ការងារគ្រោះមហន្តរាយខេត្ត
២-លោក **ធុំ សុខុម** សប្បុរសជន
៣-លោកស្រី **ហាច់ គប** សប្បុរសជន

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង ប្រធានគណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជនដែលត្រូវជូនគ្រឿងឥស្សរិយយស ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ៕

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០០៦

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល:**
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**
លេខ: ៤៦៩ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

៚

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស ឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ ប្រធានគណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជនដែលត្រូវជូនគ្រឿងឥស្សរិយយស

## សម្រេច

**មាត្រា១:** ត្រូវបានបំពាក់ **មេដាយមុនីសារាភ័ណ្ឌ** តាមលំដាប់ថ្នាក់ ប្រគេននិងជូនសប្បុរសជន ចំនួន០៤រូប ដែលមានស្នាព្រះហស្ត និងស្នាដៃល្អក្នុងការចូលរួមជួយថែរក្សាសម្បត្តិធម្មជាតិ ព្រមទាំងជួយការងារគ្រោះមហន្តរាយ នៅខេត្តឧត្តរមានជ័យ ដូចមានរាយព្រះនាមនិងនាមខាងក្រោម :-

**ក-មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ ធិបឌិន្ទ :**

១-លោក **ប៉ូល រ៉ូឡូសិន** (Mr.Paul ROELOFSON ) នាយកអង្គការ ZOA ប្រចាំប្រទេសកម្ពុជា

២-លោកស្រី **ប៊ីនី អូនៀល** (Mrs.Bernie O'NIELL ) ប្រធានអង្គការ ZOA ខេត្តឧត្តរមានជ័យ

**ខ-មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ សេនា :**

-ព្រះតេជគុណ **ម៉ិន សាលួត** ព្រះអនុគណស្រុកសំរោង /ប្រធានសង្ឃសហគមន៍ រុក្ខាវ័ន ខេត្ត

**គ-មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ អស្សប្ញទ្ធិ :**

-ព្រះតេជគុណ **ឆឹម ឃួន** ព្រះចៅអធិការវត្តរាជាសំរោង/អនុប្រធានសង្ឃសហគមន៍រុក្ខាវ័ន

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង ប្រធានគណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជនដែលត្រូវជូនគ្រឿងឥស្សរិយយស ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០០៦

**ហ៊ុន សែន**

**កន្លែងទទួល:**
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៤៣០ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ អភិបាលខេត្តឧត្តរមានជ័យ

## សម្រេច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនលោក **គង់ ខុន** ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន ក្នុងការជួយកសាង អគារសិក្សា ០១ខ្នង មាន០៣បន្ទប់ នៅស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ ដោយចំណាយអស់ថវិកា ចំនួន ១១.៨៩៥ ដុល្លារអាមេរិក ។

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលខេត្តឧត្តរមានជ័យ ត្រូវអនុវត្តអនុក្រឹត្យ នេះ អោយទទួលបានលទ្ធផលល្អ ។/.

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០០៦

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ** : ៤៣១.អនក្រ.តត

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

---

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមសំណើរបស់ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ

## សម្រេច

**មាត្រា ១:** ត្រូវបានបំពាក់ **មេដាយមុនីសារាភ័ណ្ឌ** ថ្នាក់ **អស្សឫទ្ធិ** ជូនដល់ក្រុមការងារគណៈកម្មាធិការជាតិសំរបសំរួលកិច្ចការបញ្ជូនកងកំលាំងចូលរួមប្រតិបត្តិការថែរក្សាសន្តិភាព អ.ស.ប ដែលមានស្នាដៃល្អ និងគុណបំណាច់ការងារ ដូចមានរាយនាមខាងក្រោម :

១. វរសេនីយ៍ឯក អ៊ុំ វ៉ាន់ថា
២. វរសេនីយ៍ទោ គន់ សាលី
៣. វរសេនីយ៍ត្រី កែវ សារឿន
៤. វរសេនីយ៍ត្រី ភោគ វ៉ាន់ថន
៥. អនុសេនីយឯក ស៊ាង សិនេរ
៦. លោកស្រី សួរ ដារ៉ា

**មាត្រា ២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងគណៈកម្មាធិការជាតិសំរបសំរួលកិច្ចការបញ្ជូនកងកំលាំងចូលរួមប្រតិបត្តិការថែរក្សាសន្តិភាព អ.ស.ប ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធិភាពទូលំទូលាយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៦

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និងមាត្រា ២
- រាជកិច្ច
- ឯកសារ - កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ៤៣៤ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយការងារ

---

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹតលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមសំណើរបស់ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ

## សម្រេច

**មាត្រា ១:** ត្រូវបានបំពាក់ **មេដាយមាស ការងារ** ជូនដល់ក្រុមការងារគណៈកម្មាធិការជាតិសំរបសំរួលកិច្ចការបញ្ជូនកងកំលាំងចូលរួមប្រតិបត្តិការថែរក្សាសន្តិភាព អ.ស.ប ដែលមានស្នាដៃល្អ និងគុណបំណាច់ការងារ ដូចមានរាយនាមខាងក្រោម :

១. អនុសេនីយឯក ស៊ូ សុភ័ក្រ

២. អនុសេនីយត្រី ណឹម សុវិសាល

៣. អនុសេនីយត្រី វង្ស និមល

**មាត្រា ២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងគណៈកម្មាធិការជាតិសំរបសំរួលកិច្ចការបញ្ជូនកងកំលាំងចូលរួមប្រតិបត្តិការថែរក្សាសន្តិភាព អ.ស.ប ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០០៦

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និងមាត្រា ២
- រាជកិច្ច
- ឯកសារ - កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ២៨ . សាសរ

# សេចក្តីសម្រេច

## ស្តីពី

## ការតែងតាំងសមាសភាពគណៈកម្មាធិការជាតិដោះស្រាយបញ្ហាជនអនាថា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០១ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានឃើញអនុក្រឹត្យលេខ ៥៥ អនក្រ.បក ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានឃើញអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី ១១ ខែ វិច្ឆិកា ឆ្នាំ ២០០៥ ស្តីពីការបង្កើតគណៈកម្មាធិការជាតិដោះស្រាយបញ្ហាជនអនាថា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

# ស ម្រេ ច

**ប្រការ ១**

ត្រូវបានតែងតាំងសមាសភាពគណៈកម្មាធិការជាតិដោះស្រាយបញ្ហាជនអនាថា ដូចមានរាយនាមខាងក្រោម ÷

| | | |
|---|---|---|
| ១- ឯកឧត្តម **អ៊ិត សំហេង** | រដ្ឋមន្ត្រី ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | ប្រធាន |
| ២- ឯកឧត្តម **សយ ស៊ីផុន** | រដ្ឋលេខាធិការ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | អនុប្រធានអចិន្ត្រៃយ៍ |
| ៣- ឯកឧត្តម **ខេព នន្ទី** | រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ | អនុប្រធាន |
| ៤- ឯកឧត្តម **អ៊ុំ ម៉ិនឡុង** | រដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | អនុប្រធាន |
| ៥- ឯកឧត្តម **ជា សុផារ៉ា** | រដ្ឋលេខាធិការ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | អនុប្រធាន |
| ៦- ឯកឧត្តម **ម្សាស់ លាស់** | អនុរដ្ឋលេខាធិការ ទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៧- ឯកឧត្តម **នឹម ចំន្ទតារា** | អនុរដ្ឋលេខាធិការ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | សមាជិក |
| ៨- ឯកឧត្តម **សុខ ផេង** | អនុរដ្ឋលេខាធិការ ក្រសួងសុខាភិបាល | សមាជិក |
| ៩- ឯកឧត្តម **ជា សែ** | អនុរដ្ឋលេខាធិការ ក្រសួងអប់រំ យុវជន និងកីឡា | សមាជិក |
| ១០- លោកជំទាវ **ស៊ី ដេហ៊្វីន** | អនុរដ្ឋលេខាធិការ ក្រសួងកិច្ចការនារី | សមាជិក |
| ១១- ឯកឧត្តម **ស៊ូ ស៊ុម** | អនុរដ្ឋលេខាធិការ ក្រសួងព័ត៌មាន | សមាជិក |
| ១២- ឯកឧត្តម **លឹម គន់** | អនុរដ្ឋលេខាធិការ ក្រសួងអភិវឌ្ឍន៍ជនបទ | សមាជិក |
| ១៣- ឯកឧត្តម **ស៊ឹម សួង** | អនុរដ្ឋលេខាធិការ ក្រសួងទេសចរណ៍ | សមាជិក |
| ១៤- ឯកឧត្តម **អ៊ា ស៊ឹមសិទ្ធ** | អនុរដ្ឋលេខាធិការ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | សមាជិក |
| ១៥- ឯកឧត្តម **អ៊ិន សារឿង** | អនុរដ្ឋលេខាធិការ ក្រសួងផែនការ | សមាជិក |
| ១៦- ឯកឧត្តម **កែប ជុតិមា** | អភិបាលរាជធានីភ្នំពេញ | សមាជិក |
| ១៧- លោកវេជ្ជបណ្ឌិត **ឌួន សាខុន** | អគ្គលេខាធិការរងទី ២ កាកបាទក្រហមកម្ពុជា | សមាជិក |
| ១៨- ឯកឧត្តម អភិបាលខេត្ត-ក្រុងពាក់ព័ន្ធ | | សមាជិក |

**ប្រការ ២ ._**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយពីសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ ៣ ._**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រដ្ឋមន្ត្រី រដ្ឋលេខាធិការ ក្រសួង ស្ថាប័ន និងអភិបាលខេត្ត ក្រុងពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងប្រការ ១ មានភារកិច្ចអនុវត្តសេចក្តីសម្រេចនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ, ថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០០៦*

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ដូចប្រការ ១
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ: ៧៥ . សសរ**

# សេចក្តីសម្រេច

## ស្តីពី

## ការបង្កើតក្រុមការងារអន្តរក្រសួងដើម្បីអនុវត្តកិច្ចព្រមព្រៀងរវាង រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋសង្គមនិយមវៀតណាម ស្តីពីកិច្ចសហប្រតិបត្តិការទ្វេភាគីដើម្បីលុបបំបាត់ការជួញដូរស្ត្រី និងកុមារ និងជួយដល់ជនរងគ្រោះ ដោយសារការជួញដូរ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥.០០២ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកិច្ចការនារី
- បានឃើញអនុសញ្ញា ស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទ ដែលព្រះរាជាណាចក្រកម្ពុជា បានផ្តល់សច្ចាប័ននៅថ្ងៃទី ១៥ ខែ តុលា ឆ្នាំ ១៩៩២
- បានឃើញអនុសញ្ញាស្តីពីសិទ្ធិកុមារដែលព្រះរាជាណាចក្រកម្ពុជាបានផ្តល់សច្ចាប័ននៅ ថ្ងៃទី ១៥ ខែ តុលា ឆ្នាំ ១៩៩២

- បានឃើញព្រះរាជក្រមលេខ នស/រកម/១០០៥/០៣២ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការអនុម័តយល់ព្រមលើអនុសញ្ញារបស់អង្គការអន្តរជាតិខាងការងារ លេខ ១៣២ ស្តីពីការហាមប្រាម និងសកម្មភាពបន្ទាន់ ដើម្បីការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ
- យោងសារាចរណែនាំរបស់រាជរដ្ឋាភិបាល លេខ ១៣ សរណន ចុះថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ១៩៩៩ ស្តីពីការពង្រឹង និងពង្រីកចលនាការងារប្រឆាំងនឹងការជួញដូរស្ត្រី និងកុមារ
- បានឃើញកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋសង្គមនិយមវៀតណាមស្តីពីកិច្ចសហប្រតិបត្តិការទ្វេភាគី ដើម្បីលុបបំបាត់ការជួញដូរស្ត្រី និងកុមារ និងជួយជនរងគ្រោះដោយសារការជួញដូរ ដែលបានចុះហត្ថលេខានាថ្ងៃទី ១០ ខែ តុលា ឆ្នាំ ២០០៥
- ពិនិត្យសំណូមពរការងារចាំបាច់សម្រាប់កិច្ចសហប្រតិបត្តិការដើម្បីលុបបំបាត់ការជួញដូរស្ត្រី និងកុមារ និងជួយជនរងគ្រោះដោយសារការជួញដូរ នៃប្រទេសទាំងពីរ

## ស ម្រេ ច

**ប្រការ ១ ..**

បង្កើតក្រុមការងារអន្តរក្រសួង "ដើម្បីអនុវត្តកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋសង្គមនិយមវៀតណាម ស្តីពីកិច្ចសហប្រតិបត្តិការទ្វេភាគី ដើម្បីលុបបំបាត់ការជួញដូរស្ត្រី និងកុមារ និងជួយដល់ជនរងគ្រោះដោយសារការជួញដូរ" សរសេរកាត់ថា **ក.ក.វ.ល.ជ.** ។

**ប្រការ ២ ..**

**ក.ក.វ.ល.ជ** មានសមាសភាព ដូចខាងក្រោម ÷

| | | |
|---|---|---|
| ១- រដ្ឋលេខាធិការ ក្រសួងកិច្ចការនារី | ១ រូប | ប្រធាន |
| ២- តំណាង ក្រសួងមហាផ្ទៃ | ១ រូប | អនុប្រធាន |
| ៣- អនុរដ្ឋលេខាធិការ ក្រសួងយុត្តិធម៌ | ១ រូប | អនុប្រធាន |
| ៤- អនុរដ្ឋលេខាធិការ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | ១ រូប | អនុប្រធាន |
| ៥- តំណាង ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | ១ រូប | សមាជិក |
| ៦- តំណាង ក្រសួងទេសចរណ៍ | ១ រូប | សមាជិក |
| ៧- តំណាង ក្រសួងអប់រំ យុវជន និងកីឡា | ១ រូប | សមាជិក |
| ៨- តំណាង ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | ១ រូប | សមាជិក |
| ៩- តំណាង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ១ រូប | សមាជិក |
| ១០- តំណាង ទីស្តីការគណៈរដ្ឋមន្ត្រី | ១ រូប | សមាជិក |

| | | |
|---|---|---|
| ១១- តំណាង ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី | ១ រូប | សមាជិក |
| ១២- តំណាង ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ | ១ រូប | សមាជិក |
| ១៣- តំណាង កងរាជអាវុធហត្ថលើផ្ទៃប្រទេស | ១ រូប | សមាជិក |
| ១៤- តំណាង ក្រសួងកិច្ចការនារី | ១ រូប | លេខាធិការអចិន្ត្រៃយ៍ |

**ប្រការ ៣ ..**

**គ.ក.វ.ល.ជ.** មានភារកិច្ចដូចតទៅ ÷

- រៀបចំផែនការសកម្មភាពជាតិដើម្បីអនុវត្តកិច្ចព្រមព្រៀង ឆ្នាំ ២០០៦- ២០០៧ និងបណ្តា ២ ឆ្នាំ បន្តបន្ទាប់ទៀត
- រៀបចំផែនការសកម្មភាពរួមដើម្បីអនុវត្តកិច្ចព្រមព្រៀង ដោយសហការជាមួយក្រុមការងារវៀតណាមសម្រាប់ឆ្នាំ ២០០៦-២០០៧ និងបណ្តា ២ ឆ្នាំបន្តបន្ទាប់ទៀត
- ផ្តួចផ្តើមគំនិតក្នុងការរៀបចំយុទ្ធសាស្ត្រគោលការណ៍ បទប្បញ្ញត្តិចាំបាច់នានាដើម្បីអនុវត្តកិច្ចព្រមព្រៀងនេះ
- លើកឡើងនូវអនុសាសន៍ សំដៅឱ្យមានការរីកចម្រើនតទៅទៀត នូវកិច្ចសហប្រតិបត្តិការជួយគ្នាទៅវិញទៅមករវាងប្រទេសទាំងពីរ ក្នុងការប្រយុទ្ធប្រឆាំងនឹងការជួញដូរស្ត្រី និងកុមារ
- ពិនិត្យតាមដាន និងវាយតម្លៃការអនុវត្តកិច្ចព្រមព្រៀង និងធ្វើរបាយការណ៍ជូនគណៈកម្មការរួមនៃកិច្ចសហប្រតិប្រត្តិការទ្វេភាគីកម្ពុជា និងវៀតណាម ក្នុងកិច្ចប្រជុំប្រចាំឆ្នាំរបស់ខ្លួន
- ពិនិត្យឡើងវិញ និងវាយតម្លៃនូវការអនុវត្តកិច្ចព្រមព្រៀងនេះរៀងរាល់ ២ឆ្នាំម្តង ដើម្បីដកបទពិសោធន៍ សម្រាប់ឆ្នាំបន្តទៀត និងរាយការណ៍ជូនរាជរដ្ឋាភិបាល
- ជំរុញការអនុវត្តកិច្ចព្រមព្រៀងនេះឱ្យមានប្រសិទ្ធភាព ដោយសហការជាមួយអង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិនានា
- លើកគម្រោងស្នើថវិកាជាតិ និងជំនួយពីអង្គការអន្តរជាតិនានា ដើម្បីបម្រើសកម្មភាពរបស់ក្រុមការងារនេះ
- ដោះស្រាយការខ្វែងមតិគ្នាលើការបកស្រាយ ឬការអនុវត្តកិច្ចព្រមព្រៀងនេះ តាមរយៈការចរចា។ ក្នុងករណីមិនអាចព្រមព្រៀងគ្នាតាមរយៈការចរចាទេនោះ ការខ្វែងមតិទាំងនេះត្រូវរាយការណ៍ជូនរដ្ឋាភិបាល នៃភាគីទាំងពីរដើម្បីដោះស្រាយ
- បង្កើត និងដឹកនាំប្រតិបត្តិការនៃក្រុមការងារដូចមានចែងក្នុងប្រការ ១២ នៃកិច្ចព្រមព្រៀង

**ប្រការ ៤ ..**

សមាជិក **គ.ក.វ.ល.ជ.** ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន។ ក្នុងករណីចាំបាច់ ប្រធានអាចអញ្ជើញតំណាងក្រសួង ស្ថាប័ន ឬបុគ្គលពាក់ព័ន្ធផ្សេងទៀតចូលរួមប្រជុំបាន។ ក្រុមការងារនេះមានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងកិច្ចការនារី ។

**ប្រការ ៥ .-**

**ក.ក.វ.ល.ជ.** មានលេខាធិការដ្ឋានអចិន្ត្រៃយ៍ ស្ថិតនៅនាយកដ្ឋានការពារផ្លូវច្បាប់ នៃអគ្គនាយកដ្ឋានអភិវឌ្ឍន៍សង្គម ក្រសួងកិច្ចការនារី ។

**ប្រការ ៦ .-**

ក្រុមការងារ **ក.ក.វ.ល.ជ.** ក្នុងករណីចាំបាច់អាចស្នើបង្កើតក្រុមការងារសម្របសម្រួលថ្នាក់ខេត្ត ក្រុង ដែលមាន សភាពពីតំណាងអាជ្ញាធរដែនដីដែលពាក់ព័ន្ធ ដើម្បីបង្ក្រាបការជួញដូរមនុស្ស និងផ្តល់កិច្ចការពារដល់ជនរងគ្រោះ និង ចំដំណើរការធ្វើមាតុភូមិនិវត្តន៍ស្ត្រី និងកុមារ ដែលត្រូវគេជួញដូរឆ្លងកាត់ព្រំដែនកម្ពុជា-វៀតណាម ។ ក្រុមការងារ ខេត្ត ក្រុងនេះ មានសិទ្ធិប្រើប្រាស់ត្រារបស់ខេត្ត ក្រុង ។

**ប្រការ ៧ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយពីសេចក្តីសម្រេចនេះត្រូវទុកជានិរាករណ៍ ។

**ប្រការ ៨ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកិច្ចការនារី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការពារ ពិ រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច តែយុទ្ធជន និងយុវនីតិសម្បទា រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ រដ្ឋមន្ត្រីក្រសួងទេសចរណ៍ រដ្ឋមន្ត្រីក្រសួងអប់រំយុវជន និងកីឡា មន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ ក្រសួង-ស្ថាប័នពាក់ព័ន្ធ និងបណ្តាសមាសភាព ហានចែងក្នុងប្រការ ២ មានភារកិច្ចអនុវត្តសេចក្តីសម្រេចនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០០៦*

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

លេខៈ ៤៦៥ សហវ.ប្រក. រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០០៦

# ប្រកាស

## ស្តីពីការបង្កើតគណៈកម្មការឧទ្ធរណ៍សំរាប់យន្តការអធិការកិច្ចទំនិញមុនពេលផ្ទុក

បានទទួល
ថ្ងៃទី២០ ខែ៦ ឆ្នាំ២០០៦

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រម នស/រកម/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២ នស.៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស.រកម.០១៩៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជា និងក្រុមហ៊ុន BIVAC ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០០៦ ស្តីពីអធិការកិច្ចទំនិញមុនពេលផ្ទុក
- យោងតាមតំរូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សំរេច

**ប្រការ១** : បង្កើតគណៈកម្មការឧទ្ធរណ៍សំរាប់យន្តការអធិការកិច្ចទំនិញមុនពេលផ្ទុក ដែលភាសាអង់គ្លេសហៅថា PSI Appeals Committee ។

**ប្រការ២** : គណៈកម្មការឧទ្ធរណ៍មានសមាសភាពដូចខាងក្រោម :

១. ឯកឧត្តម **ប៉ែន ស៊ីម៉ន** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជានាយកទីចាត់ការគយ និងរដ្ឋាករ ប្រធាន

| | | |
|---|---|---|
| ២. លោក គុណ ញឹម | នាយករងទីចាត់ការគយ និងរដ្ឋាករ | អនុប្រធាន |
| ៣. លោក ប៉ែន សំអាត | ប្រធានការិយាល័យលេខាធិការ និងជាប្រធានការិយាល័យវិវាទ និងច្បាប់ | អនុប្រធាន |
| ៤. លោក នួន ច័ន្ទរិទ្ធ | ប្រធានការិយាល័យបច្ចេកទេសគយ | សមាជិក |
| ៥. លោក អ៊ុយ សារិន | ប្រធានការិយាល័យត្រួតពិនិត្យ | សមាជិក |
| ៦. លោក ជា ហាក់ | ប្រធានការិយាល័យនាំចេញ | សមាជិក |
| ៧. លោក ប៊ូ ប៊ុនណារ៉ា | ជំនួយការការិយាល័យបច្ចេកទេសគយ | សមាជិក |
| ៨. លោក សង់ ស៊ីណារិទ្យ | ភ្នាក់ងារគយការិយាល័យបច្ចេកទេសគយ | សមាជិក |
| ៩. លោក សុខ សុវិទ្យា | ភ្នាក់ងារគយការិយាល័យបច្ចេកទេសគយ | សមាជិក |
| ១០. តំណាងក្រុមហ៊ុន BIVAC | | សមាជិក ។ |

**ប្រការ៣** : គណៈកម្មការឧទ្ធរណ៍មានភារៈកិច្ច ពិនិត្យដោះស្រាយរាល់ការតវ៉ា និងវិវាទទាំង ឡាយ ដែលកើតមានឡើងនៅក្នុងក្របខ័ណ្ឌនៃការអនុវត្តសេវាអធិការកិច្ចទំនិញមុនពេលផ្ទុក ។ គណៈកម្មការឧទ្ធរណ៍នេះ ត្រូវចេញសេចក្តីសំរេចវិនិច្ឆ័យលើការតវ៉ា ឬ វិវាទក្នុងរយៈពេលយ៉ាងយូរពីរសប្តាហក្រោយពេលបានទទួលសំណុំលិខិតតវ៉ា ។ ក្នុងពេលរង់ចាំការសំរេចរបស់គណៈកម្មការ ម្ចាស់ទំនិញមានសិទ្ធិយកទំនិញចេញពីគយ ដោយតំកល់ប្រាក់ធានាតាមការកំណត់របស់ទីចាត់ការគយ និងរដ្ឋាករ ។

**ប្រការ៤**: គណៈកម្មការឧទ្ធរណ៍មានសិទ្ធិអញ្ជើញមន្ត្រីឬភ្នាក់ងារគយ ឬអ្នកឯកទេសជំនាញ មកបំភ្លឺ ឬពិគ្រោះយោបល់ ។

**ប្រការ៥**: ក្នុងមួយឆមាសម្តង គណៈកម្មការឧទ្ធរណ៍ត្រូវធ្វើរបាយការណ៍សរុបពីការងាររបស់ខ្លួនជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**ប្រការ ៦**:ប្រកាស ឬសេចក្តីសំរេចណា ដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៧** : ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជានាយកទីចាត់ការគយ និង រដ្ឋាករ អគ្គលេខាធិការ នាយកខុទ្ទកាល័យ និងសាមីខ្លួនត្រូវទទួលអនុវត្តប្រកាសនេះអោយមានប្រសិទ្ធិភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

**គាត ឈន់**

**ចំលងជូន:**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- សភាពាណិជ្ជកម្មរាជធានីភ្នំពេញ
- ការិយាល័យទំនាក់ទំនងក្រុមហ៊ុន BIVAC នៅកម្ពុជា
- ដូចប្រការ៧ «ដើម្បីអនុវត្ត»

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ៤៣២ សហវ

រាជធានីភ្នំពេញ ថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៦

លិខិតចូល
ថ្ងៃទី២០ ខែមិថុនា ឆ្នាំ2006

# ប្រកាស
## ស្តីពី
## ការដាក់អោយប្រើប្រាស់គំរូរបាយការណ៍ហិរញ្ញវត្ថុ សំរាប់សហគ្រាសធុនតូចនិងមធ្យម

## ទេសរដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែកក្កដា ឆ្នាំ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតី នៃស្ថាប័នជាតិ

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២ នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

-បានឃើញអនុក្រឹត្យលេខ ០៤/អនក្រ/បក ចុះថ្ងៃទី២០ ខែ មករា ឆ្នាំ២០០០ ស្តីពីសមាសភាព និង ការប្រព្រឹត្តទៅ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-បានឃើញអនុក្រឹត្យលេខ ៧៨ /អនក្រ/បក ចុះថ្ងៃទី ១៨ ខែ វិច្ឆកា ឆ្នាំ ២០០៤ ស្តីពីការបំពេញបន្ថែម និងកែសំរួលនាយកដ្ឋានមួយចំនួននៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-បានឃើញព្រះរាជក្រមលេខ ជស/រកម/០៦៩៦/០៣ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០២/០១១ ចុះថ្ងៃទី៨ ខែកក្កដា ឆ្នាំ២០០២ ដែលប្រកាសអោយប្រើច្បាប់ស្តីពីគណនេយ្យសហគ្រាស សវនកម្មគណនេយ្យសហគ្រាស និងវិជ្ជាជីវៈគណនេយ្យ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

-បានឃើញអនុក្រឹត្យលេខ ០៨ អនប្រក.បក ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០០៣ ស្តីពីសមាសភាព និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាជាតិគណនេយ្យ

-បានឃើញប្រកាសរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុលេខ១៧០សហវ ចុះថ្ងៃ២៧ ខែមីនា ឆ្នាំ២០០៧ ស្តីពីការតែងតាំងសមាជិកក្រុមប្រឹក្សាភិបាល ប្រចាំក្រុមប្រឹក្សាជាតិគណនេយ្យ

-តាមសំណើក្រុមប្រឹក្សាជាតិគណនេយ្យ យោងតាមកំណត់ហេតុចុះថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០០៦

-យោងតាមការចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សំរេច :

**ប្រការ១ :**

ដាក់អោយសហគ្រាសធុនតូចនិងមធ្យម ក្នុងព្រះរាជាណាចក្រកម្ពុជា ដែលចែងនៅប្រការ២ខាងក្រោម ប្រើប្រាស់នូវគំរូរបាយការណ៍ស្តង់ដារមួយហៅថា " **គំរូរបាយការណ៍ហិរញ្ញវត្ថុសំរាប់សហគ្រាសធុនតូចនិងមធ្យម** " ដូចមានភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសនេះស្រាប់ ដើម្បីបង្កលក្ខណៈងាយស្រួលអោយសហគ្រាសសាមីនិមួយៗធ្វើជាឧបករណ៍ក្នុងការសុំហិរញ្ញប្បទាន ពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុឬក្នុងតម្រូវការផ្សេងៗទៀតនៅគ្រប់ពេលវេលា មុនពេលមានលទ្ធភាពរៀបចំរបាយការណ៍ហិរញ្ញវត្ថុតាមគ្រាកំណត់ ដោយអនុលោមតាមច្បាប់ និងបទបញ្ញាពាក់ព័ន្ធនានាជាធរមាន ។

**ប្រការ២ :**

ត្រូវបានចាត់ទុកថាជា " សហគ្រាសធុនតូចនិងមធ្យម " ដោយស្វ័យប្រវត្តិ តាមប្រកាសនេះ គឺសហគ្រាសពុំជាប់កាតព្វកិច្ចរៀបចំរបាយការណ៍ហិរញ្ញវត្ថុតាមស្តង់ដារគណនេយ្យកម្ពុជាទាំងឡាយណា ដែលកំពុងធ្វើសកម្មភាពអាជីវកម្ម ដោយផ្អែកលើទិន្នន័យនៃប្រតិវេទ៍ឬនៃការត្រួតពិនិត្យឃើញលើលក្ខណៈវិនិច្ឆ័យពីរក្នុងចំណោមបីដូចខាងក្រោម គឺ :

១-មានកម្មករ-និយោជិតបំរើការងារសរុបជាអតិបរមា ចាប់ពី ១១នាក់ ទៅ១០០នាក់

២-មានទឹកប្រាក់ផលរបរប្រចាំឆ្នាំ ពី១០០លានរៀល ដល់ក្រោម២៥០លានរៀល

៣-មានតម្លៃទ្រព្យសរុបពី១០០លានរៀល ដល់២៥០លានរៀល ។

**ប្រការ៣ :**

ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុតាមគំរូដែលចែងនៅប្រការ១ខាងលើ សហគ្រាសធុនតូចនិងមធ្យមសាមីនីមួយៗត្រូវទទួលខុសត្រូវចំពោះប្រតិវេទន៍របស់ខ្លួន ដោយត្រូវរ៉ាប់រងថា រាល់ទិន្នន័យដែលបានផ្តល់សុទ្ធតែបានមកពីការកាន់កាប់បញ្ជីគណនេយ្យ ឬ ស្ថិតិត្រឹមត្រូវតាមច្បាប់ និងបទបញ្ញាពាក់ព័ន្ធនានាជាធរមាន ។

**ប្រការ៤ :**

ក្រុមប្រឹក្សាជាតិគណនេយ្យត្រូវទទួលបន្ទុកចាត់ការផ្សព្វផ្សាយជាសាធារណៈ ជាពិសេសនៅមជ្ឈដ្ឋានសហគ្រាស ធុនតូចនិងមធ្យម ក៏ដូចមជ្ឈដ្ឋានគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ នូវស្មារតីនៃប្រកាសនេះនិងគំរូរបាយការណ៍ហិរញ្ញវត្ថុជាឧបសម្ព័ន្ធ ហើយតាមដានពង្រឹងការអនុវត្តន៍ រហូតបានសំរេចដល់គោលដៅ ។

**ប្រការ៥ :**

ក្រុមប្រឹក្សាជាតិគណនេយ្យ អគ្គលេខាធិការដ្ឋាន អគ្គាធិការដ្ឋាន គ្រប់នាយកដ្ឋាន-អង្គភាពពាក់ព័ន្ធនៅក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងគ្រប់សហគ្រាសធុនតូចនិងមធ្យមនៅព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះ តាមភារកិច្ចរៀង១ខ្លួន ។

**ប្រការ៦ :**

ប្រកាសនេះមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។៩.៩.៤

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

គាត ឈន់

**កន្លែងទទួល :**

-តាមប្រការ៥

"**ដើម្បីអនុវត្ត**"

-កាលប្បវត្តិ-ឯកសារ

**ចម្លងជូន :**

-ទីស្តីការគណៈរដ្ឋមន្ត្រី

" **ដើម្បីជូនជ្រាបជាព័ត៌មាន**"

-នាយកដ្ឋានរដ្ឋបាលនៃទីស្តីការគណៈរដ្ឋមន្ត្រី

" **ដើម្បីចុះផ្សាយក្នុងរាជកិច្ច**"

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ក្រុមប្រឹក្សាជាតិគណនេយ្យ

# គំរូ

# របាយការណ៍ហិរញ្ញវត្ថុ

# សំរាប់

# សហគ្រាសធុនតូច និងមធ្យម

ឆ្នាំ ២០០៦

## អារម្ភកថា

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា បានអនុម័តច្បាប់ជាច្រើនក្នុងកំឡុងប៉ុន្មានឆ្នាំនេះ ដើម្បីជួយព្រះរាជាណាចក្រកម្ពុជាក្នុងការធ្វើទំនើបភាវូបនីយកម្ម និងសមាហរណកម្មក្នុងសេដ្ឋកិច្ចពិភពលោក។ ក្នុងឆ្នាំ ២០០២ មានការតំរូវអោយរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ដែលមានចែងក្នុងច្បាប់ស្តីពីគណនេយ្យសហគ្រាស សវនកម្មគណនេយ្យសហគ្រាស និងវិជ្ជាជីវៈគណនេយ្យ ហើយក្នុងឆ្នាំ ២០០៣ មានការដាក់អោយប្រើប្រាស់ ស្តង់ដារគណនេយ្យកម្ពុជា។ គោលដៅរបស់ស្តង់ដារគណនេយ្យកម្ពុជា គឺដើម្បីផ្តល់មូលដ្ឋានសំរាប់ការកត់ត្រា និងចាត់ថ្នាក់ប្រតិបត្តិការហិរញ្ញវត្ថុ និងដើម្បីបង្កើតក្របខ័ណ្ឌសំរាប់រៀបចំរបាយការណ៍ហិរញ្ញវត្ថុ។

ក្នុងឆ្នាំ ២០០៥ ក្រុមប្រឹក្សាជាតិគណនេយ្យ រួមជាមួយ ធនាគារអភិវឌ្ឍន៍អាស៊ី និង វិទ្យាស្ថានគណនេយ្យករជំនាញនិងសវនករកម្ពុជា បានពិនិត្យមើលការអនុវត្តច្បាប់ស្តីពីគណនេយ្យសហគ្រាស សវនកម្មគណនេយ្យសហគ្រាស និងវិជ្ជាជីវៈគណនេយ្យ។ បន្ទាប់មក មានការចេញផ្សាយនូវប្រកាសថ្មីមួយដែលកំណត់កំរិតជាមូលដ្ឋានសំរាប់សហគ្រាសដែលត្រូវដាក់ជាកម្មវត្ថុនៃការធ្វើសវនកម្មស្របច្បាប់។ បន្ថែមលើការបង្កើតនូវកំរិតជាមូលដ្ឋាននេះ ប្រកាសថ្មីបានបញ្ជាក់បន្ថែមថា មានតែសហគ្រាសដែលជាកម្មវត្ថុនៃការធ្វើសវនកម្មស្របច្បាប់ទេ ដែលតំរូវអោយរៀបចំរបាយការណ៍ហិរញ្ញតាមស្តង់ដារគណនេយ្យកម្ពុជា។

នៅក្នុងដំណាក់កាលបច្ចុប្បន្ននៃការអភិវឌ្ឍន៍សេដ្ឋកិច្ច សេដ្ឋកិច្ចកម្ពុជា មានសហគ្រាសធុនតូច និង មធ្យមចំនួនច្រើន ដែលមិនតំរូវអោយរៀបចំរបាយការណ៍ហិរញ្ញវត្ថុតាមស្តង់ដារគណនេយ្យកម្ពុជាឡើយ។ ទោះបីយ៉ាងនេះក្តី សហគ្រាសធុនតូច និងមធ្យមទាំងនេះ នៅមានការលំបាកក្នុងការទទួលបានហិរញ្ញប្បទាន ដោយសារពួកគេគ្មានលទ្ធភាពផ្តល់ព័ត៌មានហិរញ្ញវត្ថុសមស្របជូនស្ថាប័នផ្តល់កំចី (ស្ថាប័នឱ្យខ្ចីប្រាក់)។

ដើម្បីជួយសហគ្រាសធុនតូច និងមធ្យមក្នុងការទទួលបានហិរញ្ញប្បទានប្រសើរជាងមុន ក្រុមប្រឹក្សាជាតិគណនេយ្យ វិទ្យាស្ថានគណនេយ្យករជំនាញនិងសវនករកម្ពុជា និងធនាគារអភិវឌ្ឍន៍អាស៊ី បានបង្កើតនូវគំរូរបាយការណ៍ហិរញ្ញវត្ថុដូចមានភ្ជាប់មកជាមួយ ដែលគំរូនេះជាផ្នែកមួយនៃជំនួយបច្ចេកទេសនៃកម្មវិធីអភិវឌ្ឍន៍សហគ្រាសធុនតូច និងមធ្យមរបស់ធនាគារអភិវឌ្ឍន៍អាស៊ី។ បន្ថែមទៅនឹងគំរូរបាយការណ៍ហិរញ្ញវត្ថុ ឯកសារនេះរួមបញ្ចូល កំណត់ពន្យល់ស្តីពីមូលដ្ឋាននៃការរៀបចំគំរូរបាយការណ៍ហិរញ្ញវត្ថុ និយមន័យនៃពាក្យនានាដែលបង្កើតបានជារបាយការណ៍ហិរញ្ញវត្ថុ និងពាក្យពេចន៍ដែលមានក្នុងគំរូរបាយការណ៍ហិរញ្ញវត្ថុ ដោយប្រើភាសាសាមញ្ញសេចក្តីសង្ខេបស្តីពីសារៈសំខាន់សំរាប់សហគ្រាសក្នុងការរក្សាកំណត់ត្រាគណនេយ្យ និង សារៈសំខាន់ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ។

អាស្រ័យហេតុនេះ ខ្ញុំសូមលើកទឹកចិត្តសហគ្រាសធុនតូច និងមធ្យម អោយប្រើប្រាស់គំរូរបាយការណ៍ហិរញ្ញវត្ថុ ដែលមានក្នុងឯកសារនេះ សំរាប់ធ្វើជាមូលដ្ឋានក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ក្នុងគោលដៅការគ្រប់គ្រងផ្ទៃក្នុងផង និង ដើម្បីដាក់ជាឯកសារសំអាងសំរាប់បង្ហាញធនាគារផងជាមួយការដាក់ពាក្យសុំខ្ចីប្រាក់។

រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែមិថុនា ឆ្នាំ ២០០៦

**អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**
**ប្រធានគណៈកម្មការកែទំរង់ប្រព័ន្ធគណនេយ្យកម្ពុជា**
**និងជា ប្រធានក្រុមប្រឹក្សាជាតិគណនេយ្យ**

**ងី តាយី**

## មាតិកា

ទំព័រ


១. ទិដ្ឋភាពទូទៅនៃគំរូរបាយការណ៍ហិរញ្ញវត្ថុសំរាប់សហគ្រាសធុនតូចនិងមធ្យម ........................ ១

២. ផលប្រយោជន៍នៃគំរូរបាយការណ៍ហិរញ្ញវត្ថុសំរាប់សហគ្រាសធុនតូចនិងមធ្យម ...................... ៤

៣. និយមន័យនៃបច្ចេកសព្ទមួយចំនួន ........................................................................ ៨

i. តារាងតុល្យការ ........................................................................ ៨

ii. របាយការណ៍លទ្ធផល ........................................................................ ១៥

iii. កំណត់សំគាល់របាយការណ៍ហិរញ្ញវត្ថុសំរាប់សហគ្រាសធុនតូចនិងមធ្យម ................ ១៧

៤. សេចក្តីណែនាំក្នុងការបំពេញរបាយការណ៍ហិរញ្ញវត្ថុសំរាប់សហគ្រាសធុនតូចនិងមធ្យម .......... ១៩

៥. គំរូរបាយការណ៍ហិរញ្ញវត្ថុសំរាប់សហគ្រាសធុនតូចនិងមធ្យម ........................................ ២១

i. គំរូរបាយការណ៍ហិរញ្ញវត្ថុសំរាប់ក្រុមហ៊ុន

ii. គំរូរបាយការណ៍ហិរញ្ញវត្ថុសំរាប់សហគ្រាសឯកកម្មសិទ្ធិ

## ទិដ្ឋភាពទូទៅ

**ទិដ្ឋភាពទូទៅ**

គំរូរបាយការណ៍ហិរញ្ញវត្ថុសំរាប់សហគ្រាសធុនតូចនិងមធ្យម (លំដាប់នេះតទៅហៅកាត់ថា គំរូរបាយការណ៍ហិរញ្ញវត្ថុ) ត្រូវបានបង្កើតឡើងដើម្បីជួយសហគ្រាសក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុមូលដ្ឋាន។ ហេតុផលចំបងក្នុងការបង្កើតគំរូរបាយការណ៍ហិរញ្ញវត្ថុនេះ គឺដើម្បីជួយសហគ្រាសអោយមានលទ្ធភាពផ្តល់ព័ត៌មានហិរញ្ញវត្ថុមូលដ្ឋាន ដោយទទួលខុសត្រូវចំពោះមុខច្បាប់ និង បទបញ្ជាពាក់ព័ន្ធនានា ជូនអ្នកឱ្យខ្ចីប្រាក់ ឬ ក្នុងគំរូវការផ្សេងៗទៀត។ លើសពីនេះ គេរំពឹងថា តាមរយៈ ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ម្ចាស់អាជីវកម្ម និងអ្នកគ្រប់គ្រងសហគ្រាស អាចយល់ដឹង និងអាចគ្រប់គ្រង អាជីវកម្មរបស់ខ្លួនបានប្រសើរជាងមុន។

គំរូរបាយការណ៍ហិរញ្ញវត្ថុជាឧបករណ៍មួយសំរាប់ជួយសហគ្រាសក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់ខ្លួន ដើម្បីប្រើប្រាស់សុំហិរញ្ញប្បទានផ្សេងៗ គ្រប់ពេលវេលា មុនពេលមានលទ្ធភាពធ្វើរបាយការណ៍ហិរញ្ញវត្ថុដែលកំណត់ដោយច្បាប់និងបទបញ្ជាជាធរមាន។

**អ្វីជាគំរូរបាយការណ៍ហិរញ្ញវត្ថុសំរាប់សហគ្រាសធុនតូចនិងមធ្យម ?**

គំរូរបាយការណ៍ហិរញ្ញវត្ថុ រួមមានផ្នែកដូចតទៅ :

១. ព័ត៌មានក្រុមហ៊ុន / ព័ត៌មានសហគ្រាស

២. របាយការណ៍របស់អភិបាល ឬរបាយការណ៍របស់ម្ចាស់សហគ្រាស

៣. តារាងតុល្យការ

៤. របាយការណ៍លទ្ធផល

៥. កំណត់សំគាល់របាយការណ៍ហិរញ្ញវត្ថុ

ការពន្យល់ចំណុចនីមួយៗនៃគំរូរបាយការណ៍ហិរញ្ញវត្ថុ មានដូចខាងក្រោម :

### ១. *ព័ត៌មានក្រុមហ៊ុន / ព័ត៌មានសហគ្រាស*

តារាងនេះ ផ្តល់ព័ត៌មានសំខាន់អំពីសហគ្រាស ដល់អ្នកអានរបាយការណ៍ហិរញ្ញវត្ថុ។

លេខចុះបញ្ជី បង្ហាញពីទ្រង់ទ្រាយគតិយុត្តិរបស់សហគ្រាស ហើយលេខបញ្ជីនេះ មានបញ្ជាក់ក្នុងលិខិតបញ្ជាក់ការចុះបញ្ជីអាជីវកម្ម ឬ លិខិតបញ្ជាក់អាជ្ញាប័ណ្ណដែលចេញផ្សាយដោយអាជ្ញាធរពាក់ព័ន្ធ។

ការិយាល័យចុះបញ្ជី ជាអាស័យដ្ឋានទីស្នាក់ការចំបងរបស់អាជីវកម្ម ហើយអាស័យដ្ឋាននេះ គប្បីជាអាស័យដ្ឋានដែលបានចុះបញ្ជីជាមួយអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ។ អាស័យដ្ឋាននេះ គួរប្រើប្រាស់ជាអាស័យដ្ឋានសំរាប់ទាក់ទងព័ត៌មាន។

ការបង្ហាញព័ត៌មានស្តីពីម្ចាស់ហ៊ុន / ម្ចាស់សហគ្រាស និង អភិបាលនិងគណៈគ្រប់គ្រងសហគ្រាស ផ្តល់ព័ត៌មានសំខាន់ស្តីពីកម្មសិទ្ធិករ និងរចនាសម្ព័ន្ធគ្រប់គ្រងសហគ្រាសដល់អ្នកអានរបាយការណ៍ហិរញ្ញវត្ថុ។ ប្រសិនបើអភិបាល និងគណៈគ្រប់គ្រង ជាបុគ្គលផ្សេងពីម្ចាស់ហ៊ុន / ម្ចាស់សហគ្រាស ព័ត៌មាននេះបញ្ជាក់ថា ម្ចាស់សហគ្រាសមិនពាក់ព័ន្ធនឹងដំណើរការអាជីវកម្មប្រចាំថ្ងៃឡើយ។

ព័ត៌មានស្តីពីធនាគារចំបង មានសារៈសំខាន់ ជាពិសេសក្នុងករណីសហគ្រាសចង់បានឥណទាន។

## 2. *របាយការណ៍របស់អភិបាល ឬម្ចាស់សហគ្រាស*

ហត្ថលេខារបស់អភិបាល / ម្ចាស់សហគ្រាសលើរបាយការណ៍ហិរញ្ញវត្ថុ ផ្តល់ការជឿទុកចិត្តដល់អ្នកប្រើប្រាស់របាយការណ៍ហិរញ្ញវត្ថុ។ តាមរយៈការចុះហត្ថលេខានេះ អភិបាល ម្ចាស់សហគ្រាស ទទួលស្គាល់ថា របាយការណ៍ហិរញ្ញវត្ថុ ត្រូវបានរៀបចំតាមគោលនយោបាយគណនេយ្យដែលមានក្នុងកំណត់សំគាល់របាយការណ៍ហិរញ្ញវត្ថុ ហើយអាចធ្វើអោយអ្នកប្រើប្រាស់របាយការណ៍ហិរញ្ញវត្ថុ ជឿជាក់លើការអនុវត្តគោលនយោបាយទាំងនេះ ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ។

ហត្ថលេខា ផ្តល់កម្មសិទ្ធិភាពលើរបាយការណ៍ហិរញ្ញវត្ថុដល់អភិបាល / ម្ចាស់សហគ្រាស។

## 3. *តារាងតុល្យការ*

តារាងតុល្យការ បង្ហាញពីស្ថានភាពហិរញ្ញវត្ថុរបស់សហគ្រាសនៅកាលបរិច្ឆេទជាក់លាក់មួយ។ ក្នុងព្រះរាជាណាចក្រកម្ពុជា តារាងតុល្យការប្រចាំឆ្នាំ ជាធម្មតាត្រូវបានរៀបចំឡើងនៅថ្ងៃទី ៣១ ខែ ធ្នូ នៃដំណាច់ឆ្នាំនីមួយៗ។

## 4. *របាយការណ៍លទ្ធផល*

របាយការណ៍លទ្ធផល បង្ហាញពីលទ្ធផលប្រតិបត្តិការរបស់សហគ្រាសសំរាប់កាលបរិច្ឆេទគណនេយ្យ។ ក្នុងព្រះរាជាណាចក្រកម្ពុជា កាលបរិច្ឆេទគណនេយ្យ ជាធម្មតា គឺនៅថ្ងៃទី ៣១ ខែ ធ្នូ នៃដំណាច់ឆ្នាំនីមួយៗ។

5. ***កំណត់សំគាល់របាយការណ៍ហិរញ្ញវត្ថុ***

កំណត់សំគាល់របាយការណ៍ហិរញ្ញវត្ថុ រួមមាន :

១. វចនាសម្ព័ន្ធ និង សកម្មភាពចំបង

២. គោលនយោបាយគណនេយ្យចំបង

៣. ការសន្មតិពាក់ព័ន្ធនឹងរបាយការណ៍ហិរញ្ញវត្ថុ

៤. ព័ត៌មានបន្ថែម

" វចនាសម្ព័ន្ធ និង សកម្មភាពចំបង " ជាព័ត៌មានសំខាន់ ព្រោះថា ព័ត៌មាននេះធ្វើអោយអ្នកប្រើប្រាស់របាយការណ៍ហិរញ្ញវត្ថុយល់ពីទ្រង់ទ្រាយគតិយុត្តិរបស់សហគ្រាស សកម្មភាពអាជីវកម្ម និងទំហំអាជីវកម្ម (ដូចជាចំនួនបុគ្គលិកជាដើម) ។

គោលនយោបាយគណនេយ្យចំបង ធ្វើអោយអ្នកអានរបាយការណ៍ហិរញ្ញវត្ថុយល់ពីគោលនយោបាយគណនេយ្យដែលប្រើប្រាស់សំរាប់រៀបចំរបាយការណ៍ហិរញ្ញវត្ថុ ។

ការសន្មតិពាក់ព័ន្ធនឹងរបាយការណ៍ហិរញ្ញវត្ថុ ផ្តល់ព័ត៌មានបន្ថែមស្តីពីរបាយការណ៍ហិរញ្ញវត្ថុ ដល់អ្នកអានរបាយការណ៍ហិរញ្ញវត្ថុ ពីបែបបទនៃការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ។

ព័ត៌មានបន្ថែម ផ្តល់ព័ត៌មានលំអិតពីសមាសភាពនីមួយៗដែលបង្ហាញក្នុងតារាងតុល្យការ និងរបាយការណ៍លទ្ធផល ។

# ផលប្រយោជន៍
# នៃគំរូរបាយការណ៍ហិរញ្ញវត្ថុសំរាប់សហគ្រាសធុនតូចនិងមធ្យម

គំរូរបាយការណ៍ហិរញ្ញវត្ថុ ត្រូវបានបង្កើតឡើងដើម្បីជួយសហគ្រាសធុនតូច និងមធ្យមក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ។ គោលដៅក្នុងការធ្វើអោយសហគ្រាសធុនតូច និងមធ្យមអាចរៀបចំរបាយការណ៍ហិរញ្ញវត្ថុជាមូលដ្ឋានបាន គឺដើម្បីអោយអ្នកគ្រប់គ្រង និងម្ចាស់សហគ្រាសធុនតូច និងមធ្យមអាចគ្រប់គ្រងអាជីវកម្មរបស់ខ្លួន និងដើម្បីទទួលបានហិរញ្ញប្បទានប្រសើរជាងមុន តាមរយៈការផ្តល់ព័ត៌មានហិរញ្ញវត្ថុមូលដ្ឋានដល់អ្នកឱ្យខ្ចីប្រាក់ដែលភាគច្រើនជាធនាគារពាណិជ្ជ។

ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ នឹងជួយសហគ្រាសធុនតូច និងមធ្យមតាមមធ្យោបាយដូចខាងក្រោម :

## ១. គ្រប់គ្រងអាជីវកម្មអោយបានប្រសើរជាងមុន

ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ផ្តល់ព័ត៌មានហិរញ្ញវត្ថុសំខាន់ដល់ម្ចាស់សហគ្រាស និងអ្នកគ្រប់គ្រងសហគ្រាសដើម្បីជួយពួកគេអោយអាចគ្រប់គ្រងសហគ្រាសបានប្រសើរជាងមុន។ របាយការណ៍លទ្ធផលផ្តល់ការវាស់វែងលទ្ធផលប្រតិបត្តិការរបស់សហគ្រាស រីឯតារាងតុល្យការវិញ បង្ហាញឱ្យឃើញស្ថានភាពរបស់អាជីវកម្មក្នុងការិយបរិច្ឆេទជាក់លាក់ណាមួយ។

### *របាយការណ៍លទ្ធផល - មធ្យោបាយវាស់វែងលទ្ធផលប្រតិបត្តិការ*

របាយការណ៍លទ្ធផល គិតជាទឹកប្រាក់នូវ លទ្ធផលប្រតិបត្តិការអាជីវកម្មក្នុងការិយបរិច្ឆេទណាមួយ។ តាមរយៈការរៀបចំរបាយការណ៍លទ្ធផល សហគ្រាសធុនតូច និងមធ្យម អាចដឹងថាសហគ្រាសរបស់ខ្លួនទទួលបានប្រាក់ចំណេញ ឬខាត។ តាមរយៈការពិនិត្យមើលរបាយការណ៍ហិរញ្ញវត្ថុ ម្ចាស់សហគ្រាស និង អ្នកគ្រប់គ្រងអាចធ្វើការសំរេចចិត្តលើប្រតិបត្តិការអាជីវកម្ម ហើយការវិភាគរបាយការណ៍លទ្ធផលនឹងជួយសហគ្រាសក្នុងការចាត់វិធានការនានា ដើម្បីអោយដំណើរការអាជីវកម្មមានលក្ខណៈប្រសើរឡើង។

ជាពិសេស ម្ចាស់សហគ្រាស និងអ្នកគ្រប់គ្រង អាចគ្រប់គ្រងចំណូល និងចំណាយរបស់អាជីវកម្មបាន។ គេចាត់ទុកប្រតិបត្តិការអាជីវកម្មថាល្អ ប្រសិនបើសហគ្រាសទទួលបានប្រាក់ចំណេញ។ ផ្ទុយមកវិញ គេចាត់ទុកប្រតិបត្តិការអាជីវកម្មថាមិនល្អ ប្រសិនបើសហគ្រាសទទួលការខាតបង់។

ឧទាហរណ៍ស្តីពីការចាត់វិធានការរបស់សហគ្រាស បន្ទាប់ពីបានត្រួតពិនិត្យមើលរបាយការណ៍ហិរញ្ញវត្ថុហើយ មានដូចខាងក្រោម :

ចំណូល : ការធ្លាក់ចុះចំណូលពីការលក់ក្នុងការិយបរិច្ឆេទ អាចបណ្តាលមកពីមូលហេតុជាច្រើនផ្សេងៗគ្នា។ ករណីនេះអាចបណ្តាលមកពីការផ្តល់សេវាកម្មដល់អតិថិជនមិនបានល្អ។ ប្រសិនបើដូច្នេះមែន អ្នកគ្រប់គ្រងអាចពិចារណាអំពីការផ្តល់វគ្គហ្វឹកហ្វឺនដល់បុគ្គលិក និង/ឬផ្តល់ប្រាក់លើកទឹកចិត្តដល់បុគ្គលិកណាដែលធ្វើអោយចំណូលពីការលក់កើនឡើង។

ចំណាយ : អ្នកគ្រប់គ្រងអាចមានផែនការកាត់បន្ថយថ្លៃដើម ដើម្បីទទួលបានប្រាក់ចំណេញជាអតិបរមា។ វិធីសាស្ត្រមួយក្នុងការកាត់បន្ថយថ្លៃដើមគឺធ្វើការចរចារថ្លៃទំនិញ និង លក្ខខណ្ឌទិញទំនិញ ជាមួយអ្នកផ្គត់ផ្គង់ទំនិញ និងសេវាកម្ម។ អប្បហារ (ការបញ្ចុះថ្លៃ) នឹងកាត់បន្ថយថ្លៃដើមនៃទំនិញដែលបានលក់ ហើយធ្វើអោយលទ្ធភាពស្វែងរកប្រាក់ចំណេញរបស់សហគ្រាសកើនឡើង។

ម្យ៉ាងវិញទៀត អ្នកគ្រប់គ្រងអាចពិនិត្យមើលមុខចំណាយណាដែលមានតំលៃខ្ពស់ និងរកមើលលទ្ធភាពកាត់បន្ថយចំណាយនេះបាន ដូចជាតាមរយៈការប្រើប្រាស់ផលិតផលផ្សេងដែលអាចជំនួសគ្នាបាន។

### *តារាងតុល្យការ - ស្ថានភាពហិរញ្ញវត្ថុ*

តារាងតុល្យការ ផ្តល់រូបភាពស្ថានភាពហិរញ្ញវត្ថុរបស់សហគ្រាសនៅការិយបរិច្ឆេទជាក់លាក់ណាមួយ។ ជាទូទៅ គេចាត់ទុកថាសហគ្រាសមួយមានស្ថានភាពហិរញ្ញវត្ថុល្អ ប្រសិនបើសហគ្រាសនោះមានទ្រព្យសកម្មច្រើនជាងទ្រព្យអកម្ម (បំណុល) និងមានប្រាក់ចំណេញជាបន្តបន្ទាប់។ ផ្ទុយមកវិញ គេចាត់ទុកថាសហគ្រាសមួយមានស្ថានភាពហិរញ្ញវត្ថុមិនល្អ ប្រសិនបើទ្រព្យអកម្មមានច្រើនជាងទ្រព្យសកម្ម និងមានការខាតបង់ជាបន្តបន្ទាប់។

តារាងតុល្យការ ក៏បង្ហាញពីលទ្ធភាពរបស់សហគ្រាសក្នុងការបំពេញកាតព្វកិច្ចនាពេលអនាគត និងបង្ហាញពីទ្រព្យសកម្មដែលមានសំរាប់ទ្រទ្រង់ការពង្រីកអាជីវកម្មនាពេលអនាគត។ តាមរយៈការពិនិត្យមើលតារាងតុល្យការ ម្ចាស់សហគ្រាស ឬអ្នកគ្រប់គ្រងសហគ្រាស អាចធ្វើការសំរេចចិត្តពីស្ថានភាពហិរញ្ញវត្ថុរបស់អាជីវកម្មបាន។

*លទ្ធភាពបង្វិលសាច់ប្រាក់*

ដើម្បីអោយអាជីវកម្មដំណើរការបានល្អនិងរីកចំរើន សហគ្រាសត្រូវមានលទ្ធភាពបំពេញកាតព្វកិច្ចហិរញ្ញវត្ថុរបស់ខ្លួននៅពេលដែលកាតព្វកិច្ចនោះដល់កាលកំណត់ត្រូវបំពេញ។ តាមភាសាសាមញ្ញ ចំណុចនេះមានន័យថា សហគ្រាសអាចទូទាត់ចំណាយក្នុងកំឡុងពេលដែលអ្នកផ្គត់ផ្គង់កំណត់។ ជាទូទៅ គេចាត់ទុកសហគ្រាសមួយថា មានលទ្ធភាពបង្វិលសាច់ប្រាក់លឿន ប្រសិនបើសហគ្រាសនោះមានទ្រព្យសកម្មរយៈពេលខ្លីច្រើនជាងទ្រព្យអកម្មរយៈពេលខ្លី។ តាមរយៈការរៀបចំតារាងតុល្យការ ម្ចាស់សហគ្រាស ឬអ្នកគ្រប់គ្រងសហគ្រាស អាចកំណត់ពីលទ្ធភាពបង្វិលជាសាច់ប្រាក់បាន។ ប្រសិនបើសហគ្រាសពិតជាមានលទ្ធភាពបង្វិលជាសាច់ប្រាក់លឿនមែន (ក្នុងករណីដែលទ្រព្យសកម្មរយៈពេលខ្លីមានលើសច្រើនជាងទ្រព្យអកម្មរយៈពេលខ្លី) នោះសហគ្រាស អាចស្ថិតក្នុងស្ថានភាពដែលអាចពង្រីកអាជីវកម្មរបស់ខ្លួនបាន។ ផ្ទុយមកវិញ ប្រសិនបើសហគ្រាសមានទ្រព្យអកម្មរយៈពេលខ្លីច្រើនជាងទ្រព្យសកម្មរយៈពេលខ្លី នោះសហគ្រាសអាចជួបប្រទះនឹងបញ្ហាហិរញ្ញវត្ថុ។

## ២. ភាពប្រសើរក្នុងការទទួលហិរញ្ញប្បទាន

ចំពោះសហគ្រាសដែលចង់ខ្ចីប្រាក់ពីធនាគារ សហគ្រាសនោះត្រូវបង្ហាញធនាគារថា សហគ្រាសរបស់ខ្លួនមានដំណើរការអាជីវកម្មល្អ ហើយអាចសងបំណុលដែលខ្ចីពីធនាគារ។ មធ្យោបាយល្អបំផុតដើម្បីបង្ហាញធនាគារអំពីស្ថានភាពហិរញ្ញវត្ថុរបស់អាជីវកម្ម គឺតាមរយៈការផ្តល់របាយការណ៍ហិរញ្ញវត្ថុ ដែលរួមមានរបាយការណ៍លទ្ធផល និងតារាងតុល្យការ។

ដូចគ្នាដែរ របាយការណ៍លទ្ធផល និងតារាងតុល្យការផ្តល់ព័ត៌មានដល់ម្ចាស់សហគ្រាស និង អ្នកគ្រប់គ្រងសហគ្រាសដើម្បីធ្វើសេចក្តីសំរេចចិត្ត រីឯធនាគារអាចធ្វើសេចក្តីសំរេចចិត្តប្រហាក់ប្រហែលនេះអំពីលទ្ធភាពរបស់សហគ្រាសក្នុងការសងបំណុលដែលសហគ្រាសខ្ចីពីធនាគារ។

ប្រសិនបើសហគ្រាសអាចផ្តល់របាយការណ៍ហិរញ្ញវត្ថុអោយធនាគារបាន នោះអាចជួយសំរួលធនាគារក្នុងការវាយតំលៃភាពជឿទុកចិត្តរបស់សហគ្រាស និងអាចកាត់បន្ថយពេលវេលាដែលធនាគារត្រូវការដើម្បីធ្វើការសំរេចចិត្តក្នុងការផ្តល់កំចី (ផ្តល់ប្រាក់អោយខ្ចី)។ លើសពីនេះ ព័ត៌មានដែលមានឯកសារបញ្ជាក់ត្រឹមត្រូវដែលបង្ហាញក្នុងរបាយការណ៍ហិរញ្ញវត្ថុសំរាប់រយៈពេលច្រើនឆ្នាំ អាចធ្វើអោយសហគ្រាសទទួលបានប្រាក់កំចីដែលមានការប្រាក់ទាប។

**៣. ការសន្សំចំណាយ**

តាមរយៈការរៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់ខ្លួនដោយផ្ទាល់ ម្ចាស់សហគ្រាស និងអ្នកគ្រប់គ្រងសហគ្រាស មិនចាំបាច់ជួលភាគីតតិយជន (ភាគីខាងក្រៅ) ឱ្យរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ដែលធ្វើឱ្យសហគ្រាសអាចសន្សំប្រាក់បានមួយចំនួន។

# និយមន័យ

## សេចក្តីផ្តើម

និយមន័យដែលមានបញ្ចូលក្នុងឯកសារនេះ បកស្រាយពាក្យពេចន៍ដែលមាននៅក្នុងគំរូរបាយការណ៍ហិរញ្ញវត្ថុ។ និយមន័យទាំងនេះ កំណត់តាមនិយមន័យនៃពាក្យពេចន៍គណនេយ្យដែលមាននៅក្នុងស្តង់ដារគណនេយ្យកម្ពុជា ប៉ុន្តែត្រូវបានកែសំរួលដើម្បីអោយអ្នកអានទូទៅ ក្រៅពីគណនេយ្យករជំនាញ ងាយយល់ពីអត្ថន័យនៃគំរូរបាយការណ៍ហិរញ្ញវត្ថុ។

## និយមន័យ

***តារាងតុល្យការ***

តារាងតុល្យការ ជារបាយការណ៍មួយដែលបង្ហាញរាល់ទ្រព្យសកម្មរបស់អាជីវកម្ម រាល់ទ្រព្យអកម្ម (បំណុល) ដែលអាជីវកម្មជំពាក់ មូលធនភាគហ៊ុន ឬដើមទុនរបស់ម្ចាស់អាជីវកម្ម និង ប្រាក់ចំណេញរក្សាទុក ក្នុងអាជីវកម្ម នៅកាលបរិច្ឆេទជាក់លាក់ណាមួយ ។ គេអាចកំណត់តារាងតុល្យការតាមសមីកាសាមញ្ញដូចខាងក្រោម :

ទ្រព្យសកម្មសរុប = ទ្រព្យអកម្មសរុប + មូលធនភាគហ៊ុន / ដើមទុនរបស់ម្ចាស់អាជីវកម្ម + ប្រាក់ចំណេញរក្សាទុក

ឬ

ទ្រព្យសកម្មសរុប - ទ្រព្យអកម្មសរុប = មូលធនភាគហ៊ុន / ដើមទុនរបស់ម្ចាស់អាជីវកម្ម + ប្រាក់ចំណេញរក្សាទុក

**ទ្រព្យសកម្ម**

ទ្រព្យសកម្មជាវត្ថុដែលអាចគិតជាតំលៃបាន និងជាកម្មសិទ្ធិរបស់អាជីវកម្ម ។

**ទ្រព្យអកម្ម**

ទ្រព្យអកម្ម ជាប្រាក់ដែលអាជីវកម្មជំពាក់បុគ្គលដទៃទៀត ។

**ទ្រព្យម្ចាស់សហគ្រាស**

ទ្រព្យម្ចាស់សហគ្រាស ជាលំអៀង (ចំនួនខុសគ្នា) រវាងទ្រព្យសកម្មរបស់អាជីវកម្ម និងទ្រព្យអកម្ម (បំណុល) ដែលអាជីវកម្មជំពាក់។ ទ្រព្យម្ចាស់សហគ្រាស ជាធម្មតា រួមមាន "មូលធនភាគហ៊ុន /ដើមទុនរបស់ម្ចាស់សហគ្រាស" និង "ប្រាក់ចំណេញ រក្សាទុក" ។

**សម្ព័ន្ធញាតិ**

ភាគីទាំងឡាយ ត្រូវបានគេចាត់ទុកថាជាសម្ព័ន្ធញាតិ (ភាគីពាក់ព័ន្ធ) ប្រសិនបើភាគីមួយមានលទ្ធភាពគ្រប់គ្រងភាគីផ្សេងទៀត ឬមានឥទ្ធិពលខ្លាំងលើភាគីផ្សេងទៀតក្នុងការធ្វើសេចក្តីសំរេចចិត្តផ្នែកហិរញ្ញវត្ថុ និងផ្នែកប្រតិបត្តិការ។

ឥទ្ធិពលខ្លាំងមានន័យថា ការចូលរួមក្នុងការសំរេចចិត្តលើគោលនយោបាយហិរញ្ញវត្ថុ និងប្រតិបត្តិការរបស់សហគ្រាស ប៉ុន្តែមិនមែនចាំបាច់គ្រប់គ្រងគោលនយោបាយទាំងនោះទេ។

**ភាគីខាងក្រៅ**

ភាគីទាំងឡាយ ត្រូវបានគេចាត់ទុកថាជា ភាគីខាងក្រៅ ប្រសិនបើភាគីនោះគ្មានលទ្ធភាពគ្រប់គ្រងភាគីផ្សេងទៀត។

**ទ្រព្យសកម្មរយៈពេលវែង**

ទ្រព្យសកម្ម ត្រូវបានចាត់ថ្នាក់ជា "ទ្រព្យសកម្មរយៈពេលវែង" ប្រសិនបើទ្រព្យសកម្មនោះត្រូវបានរំពឹងថាមានអាយុកាលប្រើប្រាស់លើសពីមួយឆ្នាំ ឬមិនត្រូវបានរំពឹងថានឹងលក់ចេញក្នុងរយៈពេលតិចជាងមួយឆ្នាំ។ ទ្រព្យសកម្មរយៈពេលវែងអាចចាត់ថ្នាក់បន្តដូចខាងក្រោម :

**ចលនទ្រព្យនិងអចលនទ្រព្យ**

ចលនទ្រព្យនិងអចលនទ្រព្យ ជាប្រភេទទ្រព្យសកម្ម ដែលសហគ្រាស :

- ប្រើប្រាស់ក្នុងការផលិត ឬផ្គត់ផ្គង់ទំនិញ ឬសេវាកម្ម
- ប្រើប្រាស់សំរាប់ការងាររដ្ឋបាល ឬ
- សំរាប់ជួលអោយភាគីដទៃដើម្បីស្វែងរកប្រាក់ចំណេញ។

ចលនទ្រព្យនិងអចលនទ្រព្យ រួមមាន អាគារ យានយន្ត ម៉ាស៊ីន សង្ហារិម និងបរិក្ខារការិយាល័យ។

**ប្រាក់ត្រូវទទួលពីសម្ព័ន្ធញាតិ**

ប្រាក់ត្រូវទទួលពីសម្ព័ន្ធញាតិ ជាប្រាក់ដែលភាគីសម្ព័ន្ធញាតិជំពាក់សហគ្រាស ហើយរំពឹងថានឹងសងវិញក្នុងរយៈពេលលើសពីមួយឆ្នាំ។

**ប្រាក់ត្រូវទទួលពីភាគីខាងក្រៅ**

ប្រាក់ត្រូវទទួលពីភាគីខាងក្រៅ ជាប្រាក់ដែលភាគីមិនមែនសម្ព័ន្ធញាតិជំពាក់សហគ្រាស ហើយរំពឹងថា គេនឹងសងវិញក្នុងរយៈពេលលើសពីមួយឆ្នាំ។

**ទ្រព្យសកម្មរយៈពេលវែងដទៃទៀត**

ទ្រព្យសកម្មរយៈពេលវែងទាំងឡាយណាដែលមិនមែនជា ចលនទ្រព្យនិងអចលនទ្រព្យ ប្រាក់ត្រូវទទួលពីសម្ព័ន្ធញាតិ ប្រាក់ត្រូវទទួលពីភាគីខាងក្រៅ ហើយមិនរំពឹងថានឹងបានទទួលក្នុងរយៈពេលមួយឆ្នាំ ត្រូវបានចាត់ថ្នាក់ជា "ទ្រព្យសកម្មរយៈពេលវែងដទៃទៀត "។

**ទ្រព្យសកម្មរយៈពេលខ្លី**

គេគប្បីចាត់ថ្នាក់ទ្រព្យសកម្មមួយថា ជាទ្រព្យសកម្មរយៈពេលខ្លី នៅពេលដែលទ្រព្យសកម្មនោះ :

ក- ត្រូវបានរំពឹងថាត្រូវលក់ ឬរក្សាទុកសំរាប់លក់ ឬប្រើប្រាស់នៅក្នុងខួបប្រតិបត្តិការ ជាប្រក្រតីរបស់សហគ្រាស ឬ

ខ- ត្រូវបានរក្សាទុកសំរាប់ធ្វើពាណិជ្ជកម្ម ឬរក្សាទុកក្នុងរយៈពេលខ្លីណាមួយ និងត្រូវបានរំពឹងថាអាចលក់ចេញជាសាច់ប្រាក់បានក្នុងរយៈពេលដប់ពីរខែ នៃកាលបរិច្ឆេទតារាងតុល្យការ ឬ

គ- ជាសាច់ប្រាក់ ឬជាសាច់ប្រាក់សមមូល (ដូចជាគណនីធនាគារ) ដែលអាចប្រើប្រាស់បានដោយគ្មានការហាមប្រាម។

ទ្រព្យសកម្មរយៈពេលខ្លី ជាទ្រព្យសកម្មដែលគេរំពឹងថា អាចប្រើប្រាស់ ឬជំនួសបានក្នុងរយៈពេល ដប់ពីរខែ នៃកាលបរិច្ឆេទតារាងតុល្យការ។

**គណនីអតិថិជន និងគណនីត្រូវទទួលផ្សេងៗ**

គណនីអតិថិជន និងគណនីត្រូវទទួលផ្សេងៗ ជាចំនួនដែលអតិថិជនជំពាក់អាជីវកម្ម។ គណនីត្រូវទទួល កើតឡើងនៅពេលដែលទំនិញ ឬសេវាកម្មត្រូវបានលក់អោយអតិថិជន ហើយអតិថិជនមិនទាន់បានទូទាត់។

**សវិធានធនសំរាប់បំណុលអាក្រក់ និងបំណុលជាប់សង្ស័យ**

បំណុលអាក្រក់ ជាបំណុលដែលមិនអាចទារបានពីអតិថិជន។ បំណុលជាប់សង្ស័យ ជាបំណុលដែលទំនងថាមិនអាចទារបានពីអតិថិជន។

សវិធានធានសំរាប់បំណុលអាក្រក់ និងបំណុលជាប់សង្ស័យ ត្រូវកត់ត្រានៅកាលបរិច្ឆេទតារាងតុល្យការ ដើម្បីប៉ាន់ស្មានបំណុលដែលគិតថាមិនអាចទារបានពីអតិថិជន។

សវិធានធនត្រូវដកចេញពីប្រាក់ចំណេញក្នុងរបាយការណ៍លទ្ធផល និងដកចេញផងដែរពី "គណនីអតិថិជន និងគណនីត្រូវទទួលផ្សេងៗ" ក្នុងតារាងតុល្យការ។

**សន្និធិ**

តាមធម្មតា សន្និធិ :

- ជាទ្រព្យសកម្មរយៈពេលខ្លីដែលទុកសំរាប់លក់ក្នុងដំណើរការអាជីវកម្មធម្មតា ឬ
- ជាទ្រព្យសកម្មរយៈពេលខ្លីដែលគេប្រើសំរាប់ផលិតទំនិញសំរាប់លក់។

សន្និធិ ជាតំលៃសន្និធិ ឬទំនិញដែលមាននៅចុងការិយបរិច្ឆេទគណនេយ្យ ហើយបរិមាណសន្និធិចុងគ្រា ត្រូវគណនាដូចខាងក្រោម :

សន្និធិចុងគ្រា = សន្និធិដើមគ្រា + បរិមាណទំនិញទិញក្នុងគ្រា + បរិមាណទំនិញផលិតក្នុងគ្រា – បរិមាណទំនិញបានលក់

**ប្រាក់ត្រូវទទួលពីសម្ព័ន្ធញាតិ**

ប្រាក់ត្រូវទទួលពីសម្ព័ន្ធញាតិ ជាប្រាក់ដែលភាគីសម្ព័ន្ធញាតិជំពាក់សហគ្រាស ហើយរំពឹងថានឹងសងក្នុងរយៈពេលមិនលើសពីមួយឆ្នាំ។

**ប្រាក់ត្រូវទទួលពីភាគីខាងក្រៅ**

ប្រាក់ត្រូវទទួលពីភាគីខាងក្រៅ ជាប្រាក់ដែលភាគីមិនមែនសម្ព័ន្ធញាតិជំពាក់សហគ្រាស ហើយរំពឹងថា នឹងសងក្នុងរយៈពេលមិនលើសពីមួយឆ្នាំ។

**សាច់ប្រាក់ និងសមតុល្យនៅធនាគារ**

ខ្ទង់នេះជាចំនួនសាច់ប្រាក់ដែលសហគ្រាសរក្សាទុក និងជាចំនួនទឹកប្រាក់ដែលមានក្នុងគណនីធនាគាររបស់សហគ្រាសនៅកាលបរិច្ឆេទតារាងតុល្យការ។

**ទ្រព្យសកម្មសរុប**

ទ្រព្យសកម្មសរុប ជាផលបូកសរុបរវាងទ្រព្យសកម្មរយៈពេលវែង និងទ្រព្យសកម្មរយៈពេលខ្លី។

**ទ្រព្យអកម្មរយៈពេលវែង**

ទ្រព្យអកម្មរយៈពេលវែង ជាចំនួនដែលសហគ្រាសជំពាក់ភាគីដទៃ ដូចជាធនាគារ និងអ្នកឱ្យខ្ចីប្រាក់ ដែលត្រូវទូទាត់ / ត្រូវសងក្នុងរយៈពេលដប់ពីរខែ។

**ប្រាក់ត្រូវសងទៅសម្ព័ន្ធញាតិ**

ប្រាក់ត្រូវសងទៅសម្ព័ន្ធញាតិ ជាប្រាក់ដែលសហគ្រាសជំពាក់ភាគីសម្ព័ន្ធញាតិ ហើយរំពឹងថានឹងសងក្នុងរយៈពេលលើសពីមួយឆ្នាំ។

**ប្រាក់ត្រូវសងទៅភាគីខាងក្រៅ**

ប្រាក់ត្រូវសងទៅភាគីខាងក្រៅ ជាប្រាក់ដែលសហគ្រាសជំពាក់ភាគីមិនមែន សម្ព័ន្ធញាតិ ហើយរំពឹងថា នឹងសងក្នុងរយៈពេលលើសពីមួយឆ្នាំ។

**ទ្រព្យអកម្មរយៈពេលខ្លី**

ទ្រព្យអកម្ម ត្រូវចាត់ថ្នាក់ជាទ្រព្យអកម្មរយៈពេលខ្លី នៅពេលដែល :

ក- ទ្រព្យអកម្មត្រូវបានរំពឹងថានឹងត្រូវទូទាត់ក្នុងខួបប្រតិបត្តិការជាប្រក្រតីរបស់សហគ្រាស ឬ

ខ- ទ្រព្យអកម្មដែលត្រូវទូទាត់ក្នុងរយៈពេលដប់ពីរខែនៃកាលបរិច្ឆេទតារាងតុល្យការ ។

ជាមូលដ្ឋាន ទ្រព្យអកម្មរយៈពេលខ្លីជាបំណុលដែលក្រុមហ៊ុនជំពាក់អ្នកផ្គត់ផ្គង់ និងម្ចាស់បំណុលរបស់ខ្លួន ។

**ឥណទានវិបារូបន៍**

ឥណទានវិបារូបន៍ (បំណុលធនាគាររយៈពេលខ្លី) ជាសាច់ប្រាក់ដែលធនាគារអនុញ្ញាតឱ្យសហគ្រាសខ្ចីក្នុងរយៈពេលខ្លី ដើម្បីបំពេញតំរូវការរបស់សហគ្រាស ។ ការផ្តល់ឥណទានវិបារូបន៍ ជាធម្មតាមានបែបបទជាផ្លូវការ ហើយតំរូវអោយសហគ្រាសដាក់ទ្រព្យធានា ។

**គណនីអ្នកផ្គត់ផ្គង់ និង គណនីត្រូវសងផ្សេងៗ**

គណនីអ្នកផ្គត់ផ្គង់ និង គណនីត្រូវសងផ្សេងៗ ជាប្រាក់ដែលសហគ្រាស ទិញទំនិញ និង សេវាកម្មដោយជំពាក់ (ក្នុងរយៈពេលដប់ពីរខែ) ។ នេះមានន័យថា ថ្លៃទំនិញ និងសេវាកម្មដល់កាលកំណត់ ត្រូវទូទាត់នៅកាលបរិច្ឆេទ បន្ទាប់ពីកាលបរិច្ឆេទលក់ទំនិញ និងសេវាកម្ម ។

**ប្រាក់ត្រូវសងទៅសម្ព័ន្ធញាតិ**

ប្រាក់ត្រូវសងទៅសម្ព័ន្ធញាតិ ជាប្រាក់ដែលសហគ្រាសជំពាក់ភាគីសម្ព័ន្ធញាតិ ហើយត្រូវបានគេរំពឹងថានឹងសងក្នុងរយៈពេលមិនលើសពីមួយឆ្នាំ។ ប្រាក់ទាំងនេះជាទូទៅជាបុរេប្រទាន (ប្រាក់អោយមុន) ពីម្ចាស់ហ៊ុន / ម្ចាស់សហគ្រាស ។

**ប្រាក់ត្រូវសងទៅភាគីខាងក្រៅ**

ប្រាក់ត្រូវសងទៅភាគីខាងក្រៅ ជាប្រាក់ដែលសហគ្រាសជំពាក់ភាគីដទៃ ដែលមិនមែនជាអតិថិជន និងមិនមែនជាភាគីសម្ព័ន្ធញាតិ ហើយត្រូវបានគេរំពឹងថានឹងសងក្នុងរយៈពេលមិនលើសពីមួយឆ្នាំ ។

**ទ្រព្យអកម្មសរុប**

ទ្រព្យអកម្មសរុប ជាផលបូករវាងទ្រព្យអកម្មរយៈពេលវែង និងទ្រព្យអកម្មរយៈពេលខ្លី ។

**ទ្រព្យម្ចាស់សហគ្រាស**

ដូចនិយមន័យមានបញ្ជាក់ខាងលើ ទ្រព្យម្ចាស់សហគ្រាស ជាលំអៀង (ចំនួនខុសគ្នា) រវាងទ្រព្យសកម្មដែលកាន់កាប់ដោយសហគ្រាស និង ទ្រព្យអកម្ម (បំណុល) ដែលសហគ្រាសជំពាក់។ ទ្រព្យម្ចាស់សហគ្រាស ជាធម្មតារួមមាន "មូលធនភាគហ៊ុន / ដើមទុនរបស ម្ចាស់សហគ្រាស" និង " ប្រាក់ចំណេញរក្សាទុក" ។

**មូលធនដែលបានបង់**

មូលធនដែលបានបង់ ជាទឹកប្រាក់ដែលម្ចាស់ហ៊ុនបានវិនិយោគ ក្នុងអាជីវកម្ម ដែលមិនអាចដកចេញពីអាជីវកម្មវិញទេរហូតដល់អាជីវកម្មត្រូវបិទទ្វារ។

**ដើមទុនរបស់ម្ចាស់សហគ្រាស**

ដើមទុនរបស់ម្ចាស់សហគ្រាសមានលក្ខណៈប្រហាក់ប្រហែលនឹងមូលធនដែលបានបង់ ហើយមានន័យថា ជាចំនួនទឹកប្រាក់ដែលម្ចាស់សហគ្រាសឯកកម្មសិទ្ធិ ឬម្ចាស់សហគ្រាស បានដាក់ក្នុងសហគ្រាស។ ដើមទុនរបស់ម្ចាស់សហគ្រាសកើនឡើង ប្រសិនបើម្ចាស់សហគ្រាសបញ្ចូលទឹកប្រាក់បន្ថែមចូលក្នុងអាជីវកម្ម ឬថយចុះ ប្រសិនបើម្ចាស់សហគ្រាសដកប្រាក់ពីអាជីវកម្ម។

**ការដកប្រាក់**

ការដកប្រាក់ មានន័យថា ម្ចាស់សហគ្រាស ដកយកសាច់ប្រាក់ចេញពីអាជីវកម្ម។

**ប្រាក់ចំណេញរក្សាទុក - ការិយបរិច្ឆេទមុន**

"ប្រាក់ចំណេញរក្សាទុក - ការិយបរិច្ឆេទមុន" ជាប្រាក់ចំណេញដែលសហគ្រាសទទួលបានក្នុងការិយបរិច្ឆេទមុនការិយបរិច្ឆេទបច្ចុប្បន្ន និងមិនទូទាត់អោយម្ចាស់សហគ្រាសឡើយ។ ប្រសិនបើសហគ្រាសមានការខាតបង់ក្នុងការិយបរិច្ឆេទមុន នោះប្រាក់ចំណេញរក្សាទុកនេះនឹងមានតំលៃអវិជ្ជមាន។

នៅក្នុងឆ្នាំដំបូងនៃដំណើរការសហគ្រាស គ្មានប្រាក់ចំណេញរក្សាទុកសំរាប់ការិយបរិច្ឆេទមុនឡើយ។

ប្រាក់ចំណេញរក្សាទុកសំរាប់ការិយបរិច្ឆេទមុន ស្មើនឹង ផលបូកប្រាក់ចំណេញ និងខាតតាំងពីការចាប់ផ្តើមអាជីវកម្មរហូតដល់ចុងការិយបរិច្ឆេទ មុនការិយបរិច្ឆេទបច្ចុប្បន្ន។

**ប្រាក់ចំណេញរក្សាទុក - ការិយបរិច្ឆេទនេះ**

ប្រាក់ចំណេញរក្សាទុកសំរាប់ការិយបរិច្ឆេទនេះជាប្រាក់ចំណេញការិយបរិច្ឆេទបច្ចុប្បន្ន ដែលមិនទូទាត់អោយម្ចាស់សហគ្រាស ។ ប្រាក់ចំណេញនេះ ត្រូវស្មើនឹង "ប្រាក់ចំណេញ/(ខាត) ក្នុងការិយបរិច្ឆេទ" ដែលបង្ហាញក្នុងរបាយការណ៍លទ្ធផល ។

**ទ្រព្យម្ចាស់សហគ្រាសសរុប**

ទ្រព្យម្ចាស់សហគ្រាសសរុប ជាផលបូករវាងមូលធនដែលបានបង់ / ដើមទុនរបស់ម្ចាស់សហគ្រាស ប្រាក់ចំណេញរក្សាទុកសំរាប់ការិយបរិច្ឆេទមុន និងប្រាក់ចំណេញរក្សាទុកសំរាប់ការិយបរិច្ឆេទនេះ និងដកចេញនូវប្រាក់ចំណេញដែលបានដក ។

**ទ្រព្យអកម្ម និង ទ្រព្យម្ចាស់សហគ្រាសសរុប**

ទ្រព្យអកម្ម និង ទ្រព្យម្ចាស់សហគ្រាសសរុប ជាផលបូករវាងទ្រព្យអកម្មសរុប និងទ្រព្យម្ចាស់សហគ្រាសសរុប ហើយត្រូវស្មើនឹងទ្រព្យសកម្មសរុប ។

***របាយការណ៍លទ្ធផល***

របាយការណ៍លទ្ធផល ជារបាយការណ៍គណនាប្រាក់ចំណេញ ឬខាត ដែលអាជីវកម្មទទួលបានក្នុងការិយបរិច្ឆេទគណនេយ្យ ដោយយក ចំណូលសរុប ដក ចំណាយសរុប ។ អាជីវកម្មទទួលបានប្រាក់ចំណេញ ប្រសិនបើចំណូលសរុបលើសចំណាយសរុប ។ ផ្ទុយមកវិញ អាជីកម្មទទួលការខាតបង់ ប្រសិនបើចំណាយសរុបលើសចំណូលសរុប ។

**ចំណូល**

ចំណូល ជាចំណូលដុលបន្ទាប់ពីកាត់ចេញអប្បហារ (ការចុះថ្លៃ) ដែលអាជីវកម្មទទួលបានពីសកម្មភាពអាជីវកម្មធម្មតា និងជាទូទៅត្រូវគណនាជាតំលៃទំនិញ និងសេវា ដែលលក់អោយអតិថិជនក្នុងការិយបរិច្ឆេទ ។

**ថ្លៃដើមនៃទំនិញ និងសេវា ដែលបានលក់**

ថ្លៃដើមនៃទំនិញ និងសេវា ដែលបានលក់អោយអតិថិជន ត្រូវគណនាដូចខាងក្រោម :

- សន្និធិដើមគ្រា (ថ្លៃដើមសន្និធិនៅដើមការិយបរិច្ឆេទ)
- បូក : ថ្លៃទំនិញដែលបានទិញសំរាប់លក់ក្នុងការិយបរិច្ឆេទ
- បូក : ថ្លៃដើមផលិតកម្មនៃទំនិញដែលបានផលិតក្នុងការិយបរិច្ឆេទ

- ដក : សន្និធិចុងគ្រា (ថ្លៃដើមសន្និធិដែលនៅចុងការិយបរិច្ឆេទ)។ សន្និធិចុងគ្រា ស្មើនឹង សន្និធិដែលបង្ហាញក្នុងតារាងតុល្យការ ក្នុងផ្នែកទ្រព្យសកម្មរយៈពេលខ្លី។

**ចំណេញដុល**

ចំណេញដុល ជាលំអៀង (ចំនួនខុសគ្នា)រវាងចំណូល និងថ្លៃដើមនៃទំនិញនិងសេវាដែលបានលក់ ហើយត្រូវគណនាដូចខាងក្រោម :

ចំណេញដុល = ចំណូល - ថ្លៃដើមនៃទំនិញ និងសេវាដែលបានលក់

គេច្រើនបង្ហាញចំណេញដុល ជាភាគរយ ហើយចំណេញដុលជួយក្នុងការវាយតំលៃលទ្ធភាពស្វែងរកប្រាក់ចំណេញរបស់សហគ្រាស។ ជាធម្មតា នៅពេលណាដែលចំណេញដុលគិតជាភាគរយកាន់តែខ្ពស់ ប្រាក់ចំណេញក៏កាន់តែខ្ពស់ដែរ។

**ចំណូលពីប្រតិបត្តិការដទៃទៀត**

ចំណូលពីប្រតិបត្តិការដទៃទៀត ជាចំណូលដែលមិនពាក់ព័ន្ធនឹងសកម្មភាពអាជីវកម្មចំបង។ ឧទាហរណ៍ ចំណូលពីប្រតិបត្តិការដទៃទៀត រួមមាន ចំណូលពីការជួល (ប្រសិនបើសកម្មភាពអាជីវកម្មចំបងមិនពាក់ព័ន្ធនឹងការជួល) ភាគលាភ ប្រាក់ចំណេញពីការលក់ចលនទ្រព្យនិងអចលនទ្រព្យ សំណងធានារ៉ាប់រង។ល។ ចំណូលពីប្រតិបត្តិការដទៃទៀតមិនរួមបញ្ចូលចំណូលការប្រាក់ទេ (ចំណូលការប្រាក់ត្រូវបង្ហាញដោយឡែក)។

**ចំណាយប្រតិបត្តិការ**

ចំណាយប្រតិបត្តិការ ជាចំណាយដែលពាក់ព័ន្ធនឹងដំណើរការអាជីវកម្ម ប៉ុន្តែមិនពាក់ព័ន្ធដោយផ្ទាល់នឹងថ្លៃដើមទំនិញនិងសេវាដែលបានលក់ឡើយ។

**ចំណេញ / (ខាត)ពីប្រតិបត្តិការ**

ចំណេញ / (ខាត)ពីប្រតិបត្តិការ ជាចំនួនលើស ឬខ្វះរវាងចំណូលពីប្រតិបត្តិការ និងចំណាយប្រតិបត្តិការ។ ចំណេញ / (ខាត)ពីប្រតិបត្តិការ ត្រូវគណនាដូចខាងក្រោម :

ចំណេញ / (ខាត) = ប្រាក់ចំណេញដុល / (ខាត)ដុល + ចំណូលពីប្រតិបត្តិការផ្សេងៗ - ចំណាយប្រតិបត្តិការ

គេអាចហៅ ចំណេញ / (ខាត)ពីប្រតិបត្តិការ ថាជា ចំណេញ / (ខាត)មុនការប្រាក់ និងមុនបង់ពន្ធផងដែរ។

**(ចំណាយ) / ចំណូលការប្រាក់**

***ចំណាយការប្រាក់***

ចំណាយការប្រាក់ ជាការប្រាក់ដែលកើតឡើងពីប្រាក់កំចីក្នុងការិយបរិច្ឆេទ ។

***ចំណូលការប្រាក់***

ចំណូលការប្រាក់ ជាចំណូលដែលទទួលបានពី :

- ប្រាក់បញ្ញើនៅធនាគារ
- ប្រាក់អោយភាគីសម្ព័ន្ធញាតិ ឬភាគីខាងក្រៅខ្ចី
- អតិថិជនដែលទូទាត់សំណងយឺតយ៉ាវ តាមលក្ខខណ្ឌបំណុលដែលជំពាក់

**ចំណេញ / (ខាត) មុនបង់ពន្ធ**

ចំណេញ / (ខាត) មុនបង់ពន្ធ ត្រូវគណនាដោយយក ចំណេញ / (ខាត) ពីប្រតិបត្តិការ (ដក) / បូក (ចំណាយ) / ចំណូលការប្រាក់សុទ្ធ ។

**ពន្ធលើប្រាក់ចំណេញ**

ពន្ធលើប្រាក់ចំណេញ ជាចំនួនពន្ធលើប្រាក់ចំណេញដែលបានបង់ជូននាយកដ្ឋានពន្ធដារក្នុងការិយបរិច្ឆេទ ។

**ចំណេញ / (ខាត) ក្នុងការិយបរិច្ឆេទ**

ចំណេញ / (ខាត) ក្នុងការិយបរិច្ឆេទ ជាលទ្ធផលនៃសកម្មភាពអាជីវកម្មទាំងអស់ដែលដំណើរការក្នុងការិយបរិច្ឆេទ ហើយត្រូវគណនាដោយយក ប្រាក់ចំណេញ / (ខាត) មុនបង់ពន្ធ ដក ពន្ធលើប្រាក់ចំណេញ ។

***កំណត់សំគាល់របាយការណ៍ហិរញ្ញវត្ថុ***

**មូលដ្ឋានគណនេយ្យបង្គរ**

តាមមូលដ្ឋាននេះ ប្រតិបត្តិការទាំងឡាយត្រូវទទួលស្គាល់ នៅពេលដែលប្រតិបត្តិការទាំងនោះកើតឡើង ដោយមិនគិតពីសាច់ប្រាក់បានទូទាត់ឬទទួលឡើយ ។ ប្រតិបត្តិការត្រូវកត់ត្រាក្នុងការិយបរិច្ឆេទគណនេយ្យ ដែលប្រតិបត្តិការទាំងនោះមានការពាក់ព័ន្ធ ។

## មូលដ្ឋានថ្លៃដើមប្រវត្តិសាស្ត្រ

មូលដ្ឋានថ្លៃដើមប្រវត្តិសាស្ត្រនៃគណនេយ្យ កត់ត្រារាល់ប្រតិបត្តិការតាមថ្លៃដើមជាក់ស្តែងនៅកាលបរិច្ឆេទប្រតិបត្តិការ។ ថ្លៃដើមប្រតិបត្តិការនីមួយៗ មិនកែតំរូវចំពោះរាល់ការផ្លាស់ប្តូរថ្លៃដើមបច្ចុប្បន្ន នៅកាលបរិច្ឆេទវាយតំលៃថ្លៃដើមជាក់លាក់ណាមួយឡើយ។

## រំលស់ចលនទ្រព្យនិងអចលនទ្រព្យ

### *រំលស់*

រំលស់ ជា"ចំណាយ" ដែលដកចេញពីចលនទ្រព្យនិងអចលនទ្រព្យលើអាយុកាលប្រើប្រាស់រំពឹងទុករបស់ចលនទ្រព្យនិងអចលនទ្រព្យនោះ។ ម្យ៉ាងវិញទៀត រំលស់ជារង្វាស់នៃការសិករិចនៃចលនទ្រព្យនិងអចលនទ្រព្យ ។

### *រំលស់ស្មើភាគ*

រំលស់ស្មើភាគ ជាចំនួនត្រូវដកចេញពីថ្លៃដើមចលនទ្រព្យនិងអចលនទ្រព្យក្នុងចំនួនស្មើៗគ្នា ក្នុងអាយុកាលប្រើប្រាស់របស់ចលនទ្រព្យនិងអចលនទ្រព្យនោះ។ ឧទាហរណ៍ ប្រសិនបើទ្រព្យសកម្ម មានអាយុកាលប្រើប្រាស់ចំនួន ៥ ឆ្នាំ ចំនួនស្មើៗគ្នាក្នុងរយៈពេល ៥ឆ្នាំត្រូវដកចេញពីថ្លៃដើមទ្រព្យសកម្មនេះ។

### *រំលស់បង្គរ*

រំលស់បង្គរ ជាតំលៃរំលស់សរុប ចាប់ផ្តើមពីកាលបរិច្ឆេទទិញទ្រព្យសកម្ម រហូតដល់ចុងការិយបរិច្ឆេទបច្ចុប្បន្ន។

### *តំលៃពិតក្នុងបញ្ជី*

តំលៃពិតក្នុងបញ្ជី ជាតំលៃចលនទ្រព្យនិងអចលនទ្រព្យ ដែលនៅសល់ពីរំលស់ នៅចុងការិយបរិច្ឆេទ ហើយគេគណនាតំលៃពិតក្នុងបញ្ជី ដូចខាងក្រោម :

តំលៃពិតក្នុងបញ្ជី = ថ្លៃដើមចលនទ្រព្យនិងអចលនទ្រព្យ កាលពីដំបូង - រំលស់បង្គរ

តំលៃពិតក្នុងបញ្ជីនៃចលនទ្រព្យនិងអចលនទ្រព្យ ត្រូវបង្ហាញក្នុងតារាងតុល្យការ។

# សេចក្តីណែនាំ
# ក្នុងការបំពេញរបាយការណ៍ហិរញ្ញវត្ថុសំរាប់សហគ្រាសធុនតូចនិងមធ្យម

គំរូរបាយការណ៍ហិរញ្ញវត្ថុ មានផ្សព្វផ្សាយក្នុងទំរង់ជាក្រដាសស្នាម ឬក្នុងប្រព័ន្ធកុំព្យូទ័រ។ សហគ្រាសអាចបញ្ចូល ព័ត៌មានហិរញ្ញវត្ថុរបស់ខ្លួនក្នុងគំរូរបាយការណ៍ហិរញ្ញវត្ថុ តាមជំហានដូចខាងក្រោម :

*ការបំពេញគំរូរបាយការណ៍ហិរញ្ញវត្ថុដោយប្រើប្រាស់កុំព្យូទ័រ*

១. ជាដំបូង សហគ្រាសលោក-លោកស្រី ត្រូវរៀបចំជាបញ្ជីមួយ ឬតារាងតុល្យភាពមួយ ដោយបញ្ជាក់អំពីចំណូល និងចំណាយ ទ្រព្យសកម្ម ទ្រព្យអកម្ម និងមូលធនទាំងអស់របស់សហគ្រាស។

២. បន្ទាប់មក លោក-លោកស្រី យកព័ត៌មានដែលមានក្នុងបញ្ជី ឬតារាងតុល្យភាពខាងលើ មកបំពេញក្នុងកំណត់សំគាល់របាយការណ៍ហិរញ្ញវត្ថុ ពីលេខ ៤ ដល់លេខ ១៦។ ព័ត៌មានលំអិតភាគច្រើន ក្នុងតារាងតុល្យការ និងរបាយការណ៍លទ្ធផល នឹងត្រូវបំពេញដោយកុំព្យូទ័រជាស្វ័យប្រវត្តិបន្ទាប់ពីព័ត៌មានទាំងនេះត្រូវបានបញ្ចូលក្នុងកំណត់សំគាល់របាយការណ៍ហិរញ្ញវត្ថុ។

៣. បំពេញ “ចំណូលប្រតិបត្តិការដទៃទៀត” និង “ពន្ធលើប្រាក់ចំណេញ ” **ដោយផ្ទាល់** ទៅក្នុងរបាយការណ៍លទ្ធផល ពីប្រភពព័ត៌មានរបស់សហគ្រាស។

៤. បំពេញ “សាច់ប្រាក់ និងសមតុល្យនៅធនាគារ ” និង “ឥណទានវិបារូបនី ” **ដោយផ្ទាល់** ក្នុងតារាងតុល្យការ ពីប្រភពព័ត៌មានរបស់សហគ្រាស។

៥. បំពេញ “ប្រាក់ចំណេញរក្សាទុក-ការិយបរិច្ឆេទមុន ”។ ព័ត៌មាននេះមានក្នុងរបាយការណ៍ហិរញ្ញវត្ថុឆ្នាំមុន។ សូមកុំបំពេញព័ត៌មាននេះ ប្រសិនបើសហគ្រាសលោក-លោកស្រីបំពេញគំរូរបាយការណ៍ហិរញ្ញវត្ថុនៅឆ្នាំដំបូង។

៦. ប្រសិនបើព័ត៌មានបំពេញបានត្រឹមត្រូវ នោះ “ទ្រព្យសកម្មសរុប ” ត្រូវស្មើ “ទ្រព្យម្ចាស់សហគ្រាស និងទ្រព្យអកម្ម សរុប” ហើយ “ប្រាក់ចំណេញរក្សាទុក-ការិយបរិច្ឆេទនេះ ” ត្រូវស្មើ “ចំណេញ / (ខាត) ក្នុងការិយបរិច្ឆេទ ” នៃរបាយការណ៍លទ្ធផល។

*ការបំពេញគំរូរបាយការណ៍ហិរញ្ញវត្ថុលើក្រដាស*

១. ជាដំបូង សហគ្រាសលោក-លោកស្រី ត្រូវរៀបចំជាបញ្ជីមួយ ឬតារាងតុល្យភាពមួយ ដោយបញ្ចូលចំណូល និងចំណាយ ទ្រព្យសកម្ម ទ្រព្យអកម្ម និងមូលធនទាំងអស់របស់សហគ្រាស។

២. បន្ទាប់មក លោក-លោកស្រី យកព័ត៌មានដែលមានក្នុងបញ្ជី ឬតារាងតុល្យភាពខាងលើ មកបំពេញក្នុងកំណត់សំគាល់របាយការណ៍ហិរញ្ញវត្ថុ ពីលេខ ៤ ដល់ លេខ ១៦។

៣. យកតំលៃសរុបក្នុងកំណត់សំគាល់របាយការណ៍ហិរញ្ញវត្ថុ ពីលេខ ៤ ដល់ លេខ ១៦ នោះ មកបំពេញក្នុងចំណុចពាក់ព័ន្ធនៅក្នុងតារាងតុល្យការ និងរបាយការណ៍លទ្ធផល។ ឧទាហរណ៍ :

*កំណត់សំគាល់របាយការណ៍ហិរញ្ញវត្ថុលេខ ៤ : ចលនទ្រព្យនិងអចលនទ្រព្យ*

យក " តំលៃក្នុងបញ្ជីសរុបនៅថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ២០XX₁ នៃខ្ទង់ចលនទ្រព្យនិងអចលនទ្រព្យសរុប " មក បំពេញក្នុងខ្ទង់ "ចលនទ្រព្យនិងអចលនទ្រព្យ ឆ្នាំ ២០XX₁ " ក្នុងតារាងតុល្យការ។

*កំណត់សំគាល់របាយការណ៍ហិរញ្ញវត្ថុលេខ ១៥ : ចំណាយប្រតិបត្តិការ*

យក " ចំណាយសរុបក្នុងខ្ទង់ឆ្នាំ ២០XX₁ " មកបំពេញក្នុងខ្ទង់ " ចំណាយប្រតិបត្តិការឆ្នាំ ២០XX₁ " ក្នុងរបាយការណ៍លទ្ធផល។

៤. បំពេញ "ចំណូលប្រតិបត្តិការដទៃទៀត" និង "ពន្ធលើប្រាក់ចំណេញ " **ដោយផ្ទាល់** ទៅក្នុងរបាយការណ៍លទ្ធផល ពីប្រភពព័ត៌មានរបស់សហគ្រាស។

៥. គណនា "ចំណេញ / (ខាត) ក្នុងការិយបរិច្ឆេទ "។

៦. បំពេញ "សាច់ប្រាក់និងសមតុល្យនៅធនាគារ " និង "ឥណទានវិបារូបន៍ " **ដោយផ្ទាល់** ទៅក្នុងតារាងតុល្យការ ពីប្រភពព័ត៌មានរបស់លោកអ្នក។

៧. បំពេញ "ប្រាក់ចំណេញរក្សាទុក-ការិយបរិច្ឆេទមុន "។ ព័ត៌មាននេះមានក្នុងរបាយការណ៍ហិរញ្ញវត្ថុឆ្នាំមុន។ សូមកុំបំពេញព័ត៌មាននេះ ប្រសិនបើសហគ្រាសលោក-លោកស្រីបំពេញគំរូរបាយការណ៍ហិរញ្ញវត្ថុនៅឆ្នាំដំបូង។

៨. បំពេញ "ប្រាក់ចំណេញរក្សាទុក-ការិយបរិច្ឆេទនេះ "ដែលមានចំនួនស្មើនឹង "ចំណេញ / (ខាត) ក្នុងការិយបរិច្ឆេទ " នៃរបាយការណ៍លទ្ធផល។

៩. ប្រសិនបើព័ត៌មានបំពេញបានត្រឹមត្រូវ នោះ "ទ្រព្យសកម្មសរុប " ត្រូវស្មើ "ទ្រព្យម្ចាស់សហគ្រាស និងទ្រព្យអកម្ម សរុប"។

គំរូរបាយការណ៍ហិរញ្ញវត្ថុសំរាប់ក្រុមហ៊ុន

# ក្រុមហ៊ុន អេប៊ីស៊ី ខូ អិលធីឌី
# របាយការណ៍ហិរញ្ញវត្ថុ
# និង
# របាយការណ៍របស់អភិបាល
# ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២OXX[1]

# ព័ត៌មានក្រុមហ៊ុន

| | |
|---|---|
| ក្រុមហ៊ុន | **អេប៊ីស៊ី ខូ អិលធីឌី** |
| លេខចុះបញ្ជី | XXXXXXXXXXXX |
| ចេញដោយ | XXXXXXXXXXXX |
| ការិយាល័យចុះបញ្ជី | XXXXXXXXXXXX<br>XXXXXXXXXXXX<br>XXXXXXXXXXXX<br>ព្រះរាជាណាចក្រកម្ពុជា |
| ម្ចាស់ហ៊ុន | XXXXXXXXXXXX |
| អភិបាល | XXXXXXXXXXXX<br>XXXXXXXXXXXX<br>XXXXXXXXXXXX |
| គណៈគ្រប់គ្រង | XXXXXXXXXXXX<br>XXXXXXXXXXXX |
| ធនាគារចំបង | XXXXXXXXXXXX |

# មាតិកា


| | | ទំព័រ |
|---|---|---|
| ១ | របាយការណ៍របស់អភិបាល | ១ |
| ២ | តារាងតុល្យការ | ២ |
| ៣ | របាយការណ៍លទ្ធផល | ៤ |
| ៤ | កំណត់សំគាល់របាយការណ៍ហិរញ្ញវត្ថុ | ៥ |

## របាយការណ៍របស់អភិបាល

យើងខ្ញុំឈ្មោះ ....................... និង ..................... ក្នុងនាមជាក្រុមប្រឹក្សាភិបាល សូមអះអាងថា របាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន អេប៊ីស៊ី ខូ អិលធីឌី (ហៅកាត់ថា "ក្រុមហ៊ុន") ដែលមានក្នុងទំព័រ .... ដល់ ..... ត្រូវបានរៀបចំឡើងដោយអនុលោមតាមគោលនយោបាយគណនេយ្យដែលបានកំណត់ក្នុងកំណត់សំគាល់ លេខ ២ និងលេខ ៣ នៃរបាយការណ៍ហិរញ្ញវត្ថុ។

(ចុះហត្ថលេខាក្នុងនាមក្រុមប្រឹក្សាភិបាលដោយស្របតាមការសំរេចរបស់អភិបាល)

______________________________

.....................................

អភិបាល

______________________________

.....................................

អភិបាល

ចុះថ្ងៃទី ..............................

**ក្រុមហ៊ុន អេប៊ីស៊ី ខូ អិលធីឌី**

**តារាងតុល្យការ**

**ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០XX1**

| | កំនត់សំគាល់ | ២០XX1<br>ពាន់រៀល | ២០XX0<br>ពាន់រៀល |
|---|---|---|---|
| **ទ្រព្យសកម្មរយៈពេលវែង** | | | |
| ចលនទ្រព្យនិងអចលនទ្រព្យ | ៤ | - | - |
| ប្រាក់ត្រូវទទួលពីសម្ព័ន្ធញាតិ | ៥ (ក) | - | - |
| ប្រាក់ត្រូវទទួលពីភាគីខាងក្រៅ | ៦ (ក) | - | - |
| ទ្រព្យសកម្មរយៈពេលវែងដទៃទៀត | | - | - |
| ទ្រព្យសកម្មរយៈពេលវែងសរុប | | - | - |
| **ទ្រព្យសកម្មរយៈពេលខ្លី** | | | |
| គណនីអតិថិជន និងគណនីត្រូវទទួលផ្សេងៗ | ៨ | - | - |
| សន្និធិ | ៧ | - | - |
| ប្រាក់ត្រូវទទួលពីសម្ព័ន្ធញាតិ | ៥ (ខ) | - | - |
| ប្រាក់ត្រូវទទួលពីភាគីខាងក្រៅ | ៦ (ខ) | - | - |
| សាច់ប្រាក់ និងសមតុល្យនៅធនាគារ | | - | - |
| ទ្រព្យសកម្មរយៈពេលខ្លីសរុប | | - | - |
| **ទ្រព្យសកម្មសរុប** | | - | - |
| **ទ្រព្យអកម្មរយៈពេលវែង** | | | |
| ប្រាក់ត្រូវសងទៅសម្ព័ន្ធញាតិ | ១០ (ក) | - | - |
| ប្រាក់ត្រូវសងទៅភាគីខាងក្រៅ | ១១ (ក) | - | - |
| **ទ្រព្យអកម្មរយៈពេលវែងសរុប** | | - | - |

**ក្រុមហ៊ុន អេប៊ីស៊ី ខូ អិលធីឌី**
**តារាងតុល្យការ (បន្ត)**
**ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០XX$_1$**

| | កំនត់សំគាល់ | ២០XX$_1$ ពាន់រៀល | ២០XX$_0$ ពាន់រៀល |
|---|---|---|---|
| **ទ្រព្យអកម្មរយៈពេលខ្លី** | | | |
| ឥណទានវិបារូបន៍ | | - | - |
| គណនីអ្នកផ្គត់ផ្គង់ និង គណនីត្រូវសងផ្សេងៗ | ៩ | - | - |
| ប្រាក់ត្រូវសងទៅសម្ព័ន្ធញាតិ | ១០ (ខ) | - | - |
| ប្រាក់ត្រូវសងទៅភាគីខាងក្រៅ | ១១ (ខ) | - | - |
| ទ្រព្យអកម្មរយៈពេលខ្លីសរុប | | - | - |
| **ទ្រព្យអកម្មសរុប** | | - | - |
| **ទ្រព្យម្ចាស់សហគ្រាស** | | | |
| មូលធនដែលបានបង់ | ១២ | - | - |
| ប្រាក់ចំណេញរក្សាទុក - ការិយបរិច្ឆេទមុន | | | |
| ប្រាក់ចំណេញរក្សាទុក - ការិយបរិច្ឆេទនេះ | | - | - |
| ទ្រព្យម្ចាស់សហគ្រាសសរុប | | - | - |
| **ទ្រព្យអកម្ម និង ទ្រព្យម្ចាស់សហគ្រាសសរុប** | | - | - |

គណនីទាំងនេះមិនត្រូវបានធ្វើសវនកម្មទេ។ កំណត់សំគាល់ដែលភ្ជាប់ជាមួយ ជាផ្នែកនៃរបាយការណ៍ហិរញ្ញវត្ថុទាំងអស់នេះ។

**ក្រុមហ៊ុន អេប៊ីស៊ី ខូ អិលធីឌី**
**របាយការណ៍លទ្ធផល**
**ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០XX$_1$**

| | កំនត់សំគាល់ | ២០XX$_1$ ពាន់រៀល | ២០XX$_0$ ពាន់រៀល |
|---|---|---|---|
| ចំណូល | ១៣ | - | - |
| ថ្លៃដើមនៃទំនិញ និងសេវាដែលបានលក់ | ១៤ | ( ) | ( ) |
| ចំណេញដុល | | - | - |
| ចំណូលពីប្រតិបត្តិការដទៃទៀត | | - | - |
| | | - | - |
| ចំណាយប្រតិបត្តិការ | ១៥ | ( ) | ( ) |
| ចំណេញ / (ខាត) ពីប្រតិបត្តិការ | | - | - |
| (ចំណាយ) / ចំណូលការប្រាក់ | ១៦ | ( ) | ( ) |
| ចំណេញ / (ខាត) មុនបង់ពន្ធ | | - | - |
| ពន្ធលើប្រាក់ចំណេញ | | ( ) | ( ) |
| ចំណេញ / (ខាត) ក្នុងការិយបរិច្ឆេទ | | - | - |

គណនីទាំងនេះមិនត្រូវបានធ្វើសវនកម្មទេ។ កំណត់សំគាល់ដែលភ្ជាប់ជាមួយ ជាផ្នែកនៃរបាយការណ៍ហិរញ្ញវត្ថុទាំងអស់នេះ

**ក្រុមហ៊ុន អេប៊ីស៊ី ខូ អិលធីឌី**
**កំណត់សំគាល់របាយការណ៍ហិរញ្ញវត្ថុ**
**ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០XX₁**

## ១. រចនាសម្ព័ន្ធ និង សកម្មភាពចំបង

ក្រុមហ៊ុនត្រូវបានបង្កើតឡើងនៅក្នុងព្រះរាជាណាចក្រកម្ពុជានៅថ្ងៃទី......................ដែលមានលេខចុះបញ្ជី ........................ និងចាប់ផ្តើមប្រតិបត្តិការនៅថ្ងៃទី........................។

សកម្មភាពចំបងរបស់ក្រុមហ៊ុន គឺ ..........................................................................................។

នៅថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០XX₁ ក្រុមហ៊ុន មាននិយោជិតចំនួន .......នាក់ (២០XX₀ : .............)។

## ២. គោលនយោបាយគណនេយ្យចំបង

### ក- មូលដ្ឋានរៀបចំ

របាយការណ៍ហិរញ្ញវត្ថុត្រូវបានរៀបចំឡើងតាមមូលដ្ឋានគណនេយ្យបង្គរ ដោយប្រើប្រាស់នូវមូលដ្ឋានថ្លៃដើមប្រវត្តិសាស្ត្រ ។

### ខ- រូបិយវត្ថុនិង ការប្តូររូបិយប័ណ្ណបរទេស

ប្រតិបត្តិការលក់និងទិញជារូបិយប័ណ្ណបរទេសត្រូវកត់ត្រាជាប្រាក់រៀលដែលមានតំលៃស្មើនៅកាលបរិច្ឆេទនៃប្រតិបត្តិការនោះ។ ចំណេញ ឬខាតរូបិយប័ណ្ណបរទេសដែលកើតឡើងដោយសារការទូទាត់លើប្រតិបត្តិការបែបនេះត្រូវទទួលស្គាល់ក្នុងរបាយការណ៍លទ្ធផល។ ទ្រព្យសកម្ម និងទ្រព្យអកម្មមានតំលៃចារឹកជារូបិយប័ណ្ណបរទេសនៅកាលបរិច្ឆេទនៃតារាងតុល្យការ ត្រូវបានរក្សាក្នុងតារាងតុល្យការតាមអត្រាប្តូរប្រាក់ ប្រវត្តិសាស្ត្រ។

### គ- ចលនទ្រព្យនិងអចលនទ្រព្យ

ក- ចលនទ្រព្យនិងអចលនទ្រព្យ ត្រូវកាត់ត្រាតាមថ្លៃដើម ដកចេញ រំលស់បង្គរ។

ខ- រំលស់

i. ដីធ្លី មិនត្រូវបានដករំលស់ឡើយ។

**ក្រុមហ៊ុន អេប៊ីស៊ី ខូ អិលធីឌី**
**កំណត់សំគាល់របាយការណ៍ហិរញ្ញវត្ថុ (បន្ត)**
**ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២OXX₁**

ii. រំលស់លើចលនទ្រព្យនិងអចលនទ្រព្យ ត្រូវកត់ត្រាជាចំណាយតាមវិធីរំលស់ស្មើភាគដោយប្រើប្រាស់ អត្រារំលស់ប្រចាំឆ្នាំដូចខាងក្រោម :

| | |
|---|---|
| អាគារ | xx% |
| កុំព្យូទ័រ កម្មវិធីកុំព្យូទ័រ និងបរិក្ខារពាក់ព័ន្ធ | xx% |
| យានយន្ត | xx% |
| សង្ហារិម និង បរិក្ខារការិយាល័យ | xx% |
| ចលនទ្រព្យនិងអចលនទ្រព្យ ផ្សេងទៀត | xx% |

## ឃ- សន្និធិ

សន្និធិត្រូវវាយតំលៃតាមតំលៃទាបបំផុតរវាងថ្លៃដើម និងថ្លៃដើមសុទ្ធ ហើយត្រូវវាយតំលៃតាមមូលដ្ឋានថ្លៃដើមមធ្យម។

## ង- គណនីត្រូវទទួល

គណនីត្រូវទទួលត្រូវវាយតំលៃតាមតំលៃកត់ត្រាដុលដោយដកចេញនូវសំវិធានធនសំរាប់បំណុលជាប់សង្ស័យ។

## ច- កំចីរយៈពេលវែង

កំចីរយៈពេលវែងត្រូវវាយតំលៃតាមតំលៃកត់ត្រា ដកចេញសំណងលើប្រាក់ដើម និងសំវិធានធនសំរាប់កំចីមិនអាចទារបាន។

## ឆ- ការជួល

ចំណាយលើការជួលទ្រព្យសកម្ម ត្រូវបានទទួលស្គាល់ជាចំណាយក្នុងការិយបរិច្ឆេទដែលចំណាយនោះកើតឡើង។

## ជ- បន្ទុកលើប្រាក់កំចី

បន្ទុកលើប្រាក់កំចី ត្រូវបានទទួលស្គាល់ជាចំណាយក្នុងការិយបរិច្ឆេទដែលបន្ទុកនោះកើតឡើង។

**ក្រុមហ៊ុន អេប៊ីស៊ី ខូ អិលធីឌី**
**កំណត់សំគាល់របាយការណ៍ហិរញ្ញវត្ថុ (បន្ត)**
**ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០XX**

## ឈ- ពន្ធលើប្រាក់ចំណេញ

ចំណាយពន្ធលើប្រាក់ចំណេញត្រូវគណនាតាមអត្រាពន្ធលើប្រាក់ចំណេញបច្ចុប្បន្នរបស់ក្រុមហ៊ុនដោយបញ្ចូលវិញនូវចំណាយដែលមិនអាចកាត់កងបាន ឬកាត់ចេញវិញចំណូលមិនជាប់ពន្ធ និងដោយមានគិតពីការខាតបង់សារពើពន្ធដែលអនុលោមតាមច្បាប់ស្តីពីសារពើពន្ធ។ ពន្ធយោងទៅការិយបរិច្ឆេទក្រោយមិនត្រូវបានទទួលស្គាល់ទេ។

## ញ- ការទទួលស្គាល់ចំណូល

ចំណូលត្រូវបានទទួលស្គាល់នៅពេលមានភាពច្បាស់លាស់ថាផលប្រយោជន៍សេដ្ឋកិច្ចពាក់ព័ន្ធនឹងប្រតិបត្តិការនឹងហូរចូលក្នុងក្រុមហ៊ុន ហើយចំណូលអាចត្រូវវាស់វែងដោយជឿជាក់បាន។ ចំណូលត្រូវបានកត់ត្រាបន្ទាប់ពីដកចេញអប្បហារ (ការចុះថ្លៃ)។

## ៣. ការសន្មតពាក់ព័ន្ធនឹងរបាយការណ៍ហិរញ្ញវត្ថុ

របាយការណ៍ហិរញ្ញវត្ថុត្រូវបានរៀបចំតាមមូលដ្ឋាននិរន្តភាពនៃដំណើរការអាជីវកម្ម ហើយគោលនយោបាយគណនេយ្យត្រូវបានអនុវត្តជាដរាបពីការិយបរិច្ឆេទមួយទៅការិយបរិច្ឆេទមួយទៀត។ ព័ត៌មានប្រៀបធៀបត្រូវបានផ្តល់ជូន ហើយតួលេខមិនសំខាន់មិនត្រូវបានបង្ហាញទេ។ របាយការណ៍ហិរញ្ញវត្ថុនេះគ្មានការកាត់កងរវាងទ្រព្យសកម្ម និងទ្រព្យអកម្មឡើយ។

**ក្រុមហ៊ុន អេប៊ីស៊ី ខូ អិលធីឌី**

**កំណត់សំគាល់របាយការណ៍ហិរញ្ញវត្ថុ (បន្ត)**

**ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០XX$_1$**

## ៤. ចលនទ្រព្យនិងអចលនទ្រព្យ

| | ដីធ្លី | អគារ | កំព្យូទ័រ កម្មវិធីកុំព្យូទ័រ និង បរិក្ខារពាក់ព័ន្ធ | យានយន្ត | សង្ហារឹម និង បរិក្ខារ ការិយាល័យ | ចលនទ្រព្យនិង អចលនទ្រព្យ ដទៃទៀត | សំណង់កំពុង សាងសង់ | ចលនទ្រព្យនិង អចលនទ្រព្យ សរុប |
|---|---|---|---|---|---|---|---|---|
| | ពាន់រៀល | ពាន់រៀល | ពាន់រៀល | ពាន់រៀល | ពាន់រៀល | ពាន់រៀល | ពាន់រៀល | ពាន់រៀល |
| **ថ្ងៃដើម** | | | | | | | | |
| នៅថ្ងៃទី ១ ខែ មករា ឆ្នាំ ២០XX$_1$ | - | - | - | - | - | - | - | - |
| ការទិញចូលបន្ថែម | - | - | - | - | - | - | - | - |
| ការដកចេញទ្រព្យសកម្ម - តាមថ្ងៃដើម | ( ) | ( ) | ( ) | ( ) | ( ) | ( ) | ( ) | ( ) |
| នៅថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០XX$_1$ | - | - | - | - | - | - | - | - |
| ដក: **រំលស់បង្គរ** | | | | | | | | |
| នៅថ្ងៃទី ១ ខែ មករា ឆ្នាំ ២០XX$_1$ | - | - | - | - | - | - | - | - |
| រំលស់ក្នុងឆ្នាំ | - | - | - | - | - | - | - | - |
| ការបញ្ចូលមកវិញក្នុងឆ្នាំ | ( ) | ( ) | ( ) | ( ) | ( ) | ( ) | ( ) | ( ) |
| នៅថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០XX$_1$ | - | - | - | - | - | - | - | - |
| **តំលៃពិតក្នុងបញ្ជី** | | | | | | | | |
| នៅថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០XX$_1$ | - | - | - | - | - | - | - | - |
| នៅថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០XX$_0$ | - | - | - | - | - | - | - | - |

**ក្រុមហ៊ុន អេប៊ីស៊ី ខូ អិលធីឌី**
**កំណត់សំគាល់របាយការណ៍ហិរញ្ញវត្ថុ (បន្ត)**
**ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០XX$_1$**

**៥- ប្រាក់ត្រូវទទួលពីសម្ព័ន្ធញាតិ**

**ក- រយៈពេលវែង**

| | ២០XX$_1$ | ២០XX$_0$ |
|---|---|---|
| | ពាន់រៀល | ពាន់រៀល |
| | - | - |
| | - | - |
| | - | - |
| | - | - |

**ខ- រយៈពេលខ្លី**

| | ២០XX$_1$ | ២០XX$_0$ |
|---|---|---|
| | ពាន់រៀល | ពាន់រៀល |
| | - | - |
| | - | - |
| | - | - |
| | - | - |

**៦- ប្រាក់ត្រូវទទួលពីភាគីខាងក្រៅ**

**ក- រយៈពេលវែង**

| | ២០XX$_1$ | ២០XX$_0$ |
|---|---|---|
| | ពាន់រៀល | ពាន់រៀល |
| | - | - |
| | - | - |
| | - | - |
| | - | - |

**ក្រុមហ៊ុន អេប៊ីស៊ី ខូ អិលធីឌី**
**កំណត់សំគាល់របាយការណ៍ហិរញ្ញវត្ថុ (បន្ត)**
**ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០XX$_1$**

**៦- រយ:ពេលខ្លី**

| | ២០XX$_1$ | ២០XX$_0$ |
|---|---|---|
| | ពាន់រៀល | ពាន់រៀល |
| | - | - |
| | - | - |
| | - | - |
| | - | - |

**៧- សន្និធិ**

| | ២០XX$_1$ | ២០XX$_0$ |
|---|---|---|
| | ពាន់រៀល | ពាន់រៀល |
| | - | - |
| | - | - |
| | - | - |
| | - | - |

**៨- គណនីអតិថិជន និងគណនីត្រូវទទួលផ្សេងៗ**

| | ២០XX$_1$ | ២០XX$_0$ |
|---|---|---|
| | ពាន់រៀល | ពាន់រៀល |
| | - | - |
| | - | - |
| | - | - |
| ដក : សំវិធានធនសំរាប់បំណុលជាប់សង្ស័យ | ( ) | ( ) |
| | - | - |

**ក្រុមហ៊ុន អេប៊ីស៊ី ខូ អិលធីឌី**
**កំណត់សំគាល់របាយការណ៍ហិរញ្ញវត្ថុ (បន្ត)**
**ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០XX₁**

**៩. គណនីអ្នកផ្គត់ផ្គង់ និង គណនីត្រូវសងផ្សេងៗ**

| | ២០XX₁ | ២០XX₀ |
|---|---|---|
| | ពាន់រៀល | ពាន់រៀល |
| | - | - |
| | - | - |
| | - | - |
| | - | - |

**១០. ប្រាក់ត្រូវសងទៅសម្ព័ន្ធញាតិ**

**ក- រយៈពេលវែង**

| | ២០XX₁ | ២០XX₀ |
|---|---|---|
| | ពាន់រៀល | ពាន់រៀល |
| | - | - |
| | - | - |
| | - | - |
| | - | - |

**ខ- រយៈពេលខ្លី**

| | ២០XX₁ | ២០XX₀ |
|---|---|---|
| | ពាន់រៀល | ពាន់រៀល |
| | - | - |
| | - | - |
| | - | - |
| | - | - |

**ក្រុមហ៊ុន អេប៊ីស៊ី ខូ អិលធីឌី**
**កំណត់សំគាល់របាយការណ៍ហិរញ្ញវត្ថុ (បន្ត)**
**ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០XX$_1$**

**១១. ប្រាក់ត្រូវសងទៅភាគីខាងក្រៅ**

**ក- រយៈពេលវែង**

| | ២០XX$_1$ | ២០XX$_0$ |
|---|---|---|
| | ពាន់រៀល | ពាន់រៀល |
| | - | - |
| | - | - |
| | - | - |
| | - | - |

**ខ- រយៈពេលខ្លី**

| | ២០XX$_1$ | ២០XX$_0$ |
|---|---|---|
| | ពាន់រៀល | ពាន់រៀល |
| | - | - |
| | - | - |
| | - | - |
| | - | - |

**១២. មូលធនភាគហ៊ុន**

| ឈ្មោះម្ចាស់ហ៊ុន | ២០XX$_1$ | ២០XX$_0$ |
|---|---|---|
| | ពាន់រៀល | ពាន់រៀល |
| | - | - |
| | - | - |
| | - | - |
| | - | - |

**ក្រុមហ៊ុន អេប៊ីស៊ី ខូ អិលធីឌី**
**កំណត់សំគាល់របាយការណ៍ហិរញ្ញវត្ថុ (បន្ត)**
**ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០XX$_1$**

**១៣. ចំណូល**

| | ២០XX$_1$ ពាន់រៀល | ២០XX$_0$ ពាន់រៀល |
|---|---|---|
| [រាយប្រភេទចំណូលផ្សេងៗ ប្រសិនបើចាំបាច់] | - | - |
| | - | - |
| | - | - |
| | - | - |

**១៤. ថ្លៃដើមនៃទំនិញដែលបានលក់**

| | ២០XX$_1$ ពាន់រៀល | ២០XX$_0$ ពាន់រៀល |
|---|---|---|
| សន្និធិដើមគ្រា | - | - |
| ការទិញ | - | - |
| ថ្លៃដើមផលិតកម្ម | - | - |
| | - | - |
| សន្និធិចុងគ្រា | ( ) | ( ) |
| ថ្លៃដើមនៃទំនិញដែលបានលក់ | - | - |

**ក្រុមហ៊ុន អេប៊ីស៊ី ខូ អិលធីឌី**

**កំណត់សំគាល់របាយការណ៍ហិរញ្ញវត្ថុ (បន្ត)**

**ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០XX$_1$**

## ១៥. ចំណាយប្រតិបត្តិការ

| | ២០XX$_1$ | ២០XX$_0$ |
|---|---|---|
| | ពាន់រៀល | ពាន់រៀល |
| ផ្សាយពាណិជ្ជកម្ម | - | - |
| សវនកម្ម និងគណនេយ្យ | - | - |
| បំណុលអាក្រក់ | - | - |
| សេវាធនាគារ | - | - |
| រំលស់ | - | - |
| លាភការនិយោជិត | - | - |
| ការកំសាន្ត | - | - |
| អត្ថប្រយោជន៍បន្ថែម | - | - |
| ម្ហូប និង ការស្នាក់នៅ - ចំណាយបេសកកម្ម | - | - |
| កំរៃវិជ្ជាជីវៈ | - | - |
| ការជួល | - | - |
| ជួសជុល និង ថែទាំ | - | - |
| អ្នកម៉ៅការបន្ត | - | - |
| ពន្ធដារ និង ពន្ធអាករ | - | - |
| ដឹកជញ្ជូន | - | - |
| | - | - |

ចំណាយបន្ថែមផ្សេងទៀត អាចបញ្ចូលបាន ក្នុងករណីសមស្រប ។

**ក្រុមហ៊ុន អេប៊ីស៊ី ខូ អិលធីឌី**
**កំណត់សំគាល់របាយការណ៍ហិរញ្ញវត្ថុ (បន្ត)**
**ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០XX$_1$**

## ១៦. ចំណាយការប្រាក់

| | ២០XX$_1$ ពាន់រៀល | ២០XX$_0$ ពាន់រៀល |
|---|---|---|
| ចំណូលការប្រាក់ | ( ) | ( ) |
| ចំណេញបានពីការប្តូរប្រាក់ | ( ) | ( ) |
| | ( ) | ( ) |
| ចំណាយការប្រាក់ | - | - |
| ខាតមកពីការប្តូរប្រាក់ | - | - |
| | - | - |
| ចំណាយការប្រាក់សុទ្ធ / (ចំណូលការប្រាក់សុទ្ធ) | - | - |

គំរូរបាយការណ៍ហិរញ្ញវត្ថុសំរាប់សហគ្រាសឯកបុគ្គល

# លោក អេអេអេ អ៊ិចវាយហ្សិត
# ដំណើរការអាជីវកម្មក្នុងនាមជា
# សហគ្រាស អ៊ិចវាយហ្សិត

# របាយការណ៍ហិរញ្ញវត្ថុ
# និង
# របាយការណ៍របស់ម្ចាស់សហគ្រាស
# ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២OXX[1]

# ព័ត៌មានសហគ្រាស

| | |
|---|---|
| សហគ្រាស | **អ៊ិចវាយហ្សិត** |
| លេខចុះបញ្ជី | XXXXXXXXXXXX |
| ចេញដោយ | XXXXXXXXXXXX |
| អាស័យដ្ឋានអាជីវកម្ម | XXXXXXXXXXXX<br>XXXXXXXXXXXX<br>XXXXXXXXXXXX<br>ព្រះរាជាណាចក្រកម្ពុជា |
| ឈ្មោះម្ចាស់សហគ្រាស | លោក អេអេអេ អ៊ិចវាយហ្សិត |
| គណៈគ្រប់គ្រង | XXXXXXXXXXXX<br>XXXXXXXXXXXX |
| ធនាគារចំបង | XXXXXXXXXXXX |

# មាតិកា


| | | ទំព័រ |
|---|---|---|
| ១ | របាយការណ៍របស់ម្ចាស់សហគ្រាស | ១ |
| ២ | ទារាងតុល្យការ | ២ |
| ៣ | របាយការណ៍លទ្ធផល | ៤ |
| ៤ | កំណត់សំគាល់របាយការណ៍ហិរញ្ញវត្ថុ | ៥ |

## សេចក្តីថ្លែងការណ៍របស់ម្ចាស់សហគ្រាស

ខ្ញុំឈ្មោះ ........................ ជាម្ចាស់សហគ្រាស សូមអះអាងថា របាយការណ៍ហិរញ្ញវត្ថុ របស់សហគ្រាស អ៊ិចវ៉ាយហ្សិត (ហៅកាត់ថា "សហគ្រាស ") ដែលមានក្នុងទំព័រ .... ដល់ ..... ត្រូវបានរៀបចំឡើងដោយអនុលោមតាមគោលនយោបាយគណនេយ្យដែលបានកំណត់ក្នុងកំណត់សំគាល់ លេខ ២ និងលេខ ៣ នៃរបាយការណ៍ហិរញ្ញវត្ថុ។

(ចុះហត្ថលេខាដោយ)

---

លោក អេអេអេ អ៊ិចវ៉ាយហ្សិត

ម្ចាស់សហគ្រាស

**សហគ្រាស អ៊ិចវាយហ្ស៊ិត**

**តារាងតុល្យការ**

**ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០XX₁**

| | កំនត់សំគាល់ | ២០XX₁ ពាន់រៀល | ២០XX₀ ពាន់រៀល |
|---|---|---|---|
| **ទ្រព្យសកម្មរយៈពេលវែង** | | | |
| ចលនទ្រព្យនិងអចលនទ្រព្យ | ៤ | - | - |
| ប្រាក់ត្រូវទទួលពីសម្ព័ន្ធញាតិ | ៥ (ក) | - | - |
| ប្រាក់ត្រូវទទួលពីភាគីខាងក្រៅ | ៦ (ក) | - | - |
| ទ្រព្យសកម្មរយៈពេលវែងដទៃទៀត | | - | - |
| ទ្រព្យសកម្មរយៈពេលវែងសរុប | | - | - |
| **ទ្រព្យសកម្មរយៈពេលខ្លី** | | | |
| គណនីអតិថិជន និងគណនីត្រូវទទួលផ្សេងៗ | ៨ | - | - |
| សន្និធិ | ៧ | - | - |
| ប្រាក់ត្រូវទទួលពីសម្ព័ន្ធញាតិ | ៥ (ខ) | - | - |
| ប្រាក់ត្រូវទទួលពីភាគីខាងក្រៅ | ៦ (ខ) | - | - |
| សាច់ប្រាក់ និងសមតុល្យនៅធនាគារ | | - | - |
| ទ្រព្យសកម្មរយៈពេលខ្លីសរុប | | - | - |
| **ទ្រព្យសកម្មសរុប** | | - | - |
| **ទ្រព្យអកម្មរយៈពេលវែង** | | | |
| ប្រាក់ត្រូវសងទៅសម្ព័ន្ធញាតិ | ១០ (ក) | - | - |
| ប្រាក់ត្រូវសងទៅភាគីខាងក្រៅ | ១១ (ក) | - | - |
| **ទ្រព្យអកម្មរយៈពេលវែងសរុប** | | - | - |

**សហគ្រាស អ៊ិចទាយហ្សិត**

**តារាងតុល្យការ (បន្ត)**

**ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០XX$_1$**

| | កំនត់សំគាល់ | ២០XX$_1$ ពាន់រៀល | ២០XX$_0$ ពាន់រៀល |
|---|---|---|---|
| **ទ្រព្យអកម្មរយៈពេលខ្លី** | | | |
| ឥណទានវិបារូបនី | | - | - |
| គណនីអ្នកផ្គត់ផ្គង់ និង គណនីត្រូវសងផ្សេងៗ | ៩ | - | - |
| ប្រាក់ត្រូវសងទៅសម្ព័ន្ធញាតិ | ១០ (ខ) | - | - |
| ប្រាក់ត្រូវសងទៅភាគីខាងក្រៅ | ១១ (ខ) | - | - |
| ទ្រព្យអកម្មរយៈពេលខ្លីសរុប | | - | - |
| **ទ្រព្យអកម្មសរុប** | | - | - |
| | | | |
| **ទ្រព្យម្ចាស់សហគ្រាស** | | | |
| ដើមទុនរបស់ម្ចាស់សហគ្រាស | ១២ | - | - |
| ប្រាក់ចំណេញរក្សាទុក -ការិយបរិច្ឆេទមុន | | - | - |
| ប្រាក់ចំណេញរក្សាទុក - ការិយបរិច្ឆេទនេះ | | - | - |
| ការដកប្រាក់ | | ( ) | ( ) |
| ទ្រព្យម្ចាស់សហគ្រាសសរុប | | - | - |
| **ទ្រព្យអកម្ម និង ទ្រព្យម្ចាស់សហគ្រាសសរុប** | | - | - |

គណនីទាំងនេះមិនត្រូវបានធ្វើសវនកម្មទេ។ កំណត់សំគាល់ដែលភ្ជាប់ជាមួយ ជាផ្នែកនៃរបាយការណ៍ហិរញ្ញវត្ថុទាំងអស់នេះ។

**សហគ្រាស អ៊ិចវាយហ្សិត**
**របាយការណ៍លទ្ធផល**
**ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០XX$_1$**

| | កំនត់សំគាល់ | ២០XX$_1$ ពាន់រៀល | ២០XX$_0$ ពាន់រៀល |
|---|---|---|---|
| ចំណូល | ១៣ | - | - |
| ថ្លៃដើមនៃទំនិញនិងសេវាដែលបានលក់ | ១៤ | ( ) | ( ) |
| ចំណេញដុល | | - | - |
| ចំណូលពីប្រតិបត្តិការដទៃ | | - | - |
| | | - | - |
| ចំណាយប្រតិបត្តិការ | ១៥ | ( ) | ( ) |
| ចំណេញ / (ខាត) ពីប្រតិបត្តិការ | | - | - |
| (ចំណាយ) / ចំណូលការប្រាក់ | ១៦ | ( ) | ( ) |
| ចំណេញ / (ខាត) មុនបង់ពន្ធ | | - | - |
| ពន្ធលើប្រាក់ចំណេញ | | ( ) | ( ) |
| ចំណេញ / (ខាត) ក្នុងការិយបរិច្ឆេទ | | - | - |

**សហគ្រាស អ៊ិចវាយហ្សិត**
**កំណត់សំគាល់របាយការណ៍ហិរញ្ញវត្ថុ**
**ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០XX₁**

គណនីទាំងនេះមិនត្រូវបានធ្វើសវនកម្មទេ ។ កំណត់សំគាល់ដែលភ្ជាប់ជាមួយ ជាផ្នែកនៃរបាយការណ៍ហិរញ្ញវត្ថុទាំងអស់នេះ ។

## ១. រចនាសម្ព័ន្ធ និង សកម្មភាពចំបង

សហគ្រាស ត្រូវបានបង្កើតឡើងនៅក្នុងព្រះរាជាណាចក្រកម្ពុជានៅថ្ងៃទី...................ដែលមានលេខចុះបញ្ជី .................. និងចាប់ផ្តើមប្រតិបត្តិការនៅថ្ងៃទី....................... ។

សកម្មភាពចំបងរបស់សហគ្រាស គឺ .......................................................................................... ។

នៅថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០XX₁ សហគ្រាស មាននិយោជិតចំនួន .......នាក់ (២០XX₀ : .............) ។

## ២. គោលនយោបាយគណនេយ្យចំបង

### ក- មូលដ្ឋានរៀបចំ

